"Roeung" Neang Chompathong" R-62-




B-5-3
D-86
N-296
INDOCHINE
06

# សៀវភៅដែលផ្សាយចេញពីគេហស្ថាន គីម-គី

| | | |
|---|---|---|
| ច្បាប់បរទ្បាន . . . . . . . . . . . . . | ១ សៀវភៅថ្លៃ | ១០៛០០ |
| ព្រះគោព្រះកែវ ទី ១ ដល់ទី ៧ ចប់ . . . | ,, | ៨៛០០ |
| តេជោដំឌិន ទី ១ ដល់ទី ៧ ចប់ . . . . . | ,, | ៨៛០០ |
| ទឹករំផ្កាកាំ ទី ១ ទី ២ ចប់ . . . . . . | ,, | ៨៛០០ |
| កាព្យកំសាន្តចិត្ត . . . . . . . . . . | ,, | ៦៛០០ |
| រឿងធន្ទមឿង ទី ១ ទី ២ ចប់ . . . . | ,, | ៨៛០០ |
| រឿងធ្មេញជ័យ . . . . . . . . . . | ,, | ១២៛០០ |
| រឿងអាឡាដាំងមនុស្សមាត់ទិព្វចង្កៀងទិព្វ | ,, | ១៤៛០០ |
| រឿងព្រះសុធន នាងកែវមនោរា ទី ១ ទី ២ ចប់ | ,, | ៩៛០០ |
| រឿងវិបុលសគ្រាមទី ១ . . . . . . . | ,, | ១០៛០០ |
| ,, ,, ទី ២ . . . . . . . | ,, | ១៤៛០០ |
| ,, ,, ទី ៣ . . . . . . . | ,, | ១២៛០០ |
| នាងពីរដណ្ដប់ ពុទ្ធសែននាងកង្រី . . . | ,, | ១០៛០០ |
| ព្រះបន្ទុគោរប់ ទី ១ ទី ២ . . . . . | ,, | ១០៛០០ |
| ,, ,, ទី ៣ ចប់ . . . . . . | ,, | ១២៛០០ |
| កុមារផ្ដាន . . . . . . . . . . | ,, | ១០៛០០ |
| រឿងទាវឯក ទី ១ ទី ២ ទី ៣ ទី ៤ . . | ,, | ៤៛០០ |
| សេកសារិកា . . . . . . . . . . | ,, | ៧៛០០ |
| រឿងជ័យសុរិន្ទ្រ ទី ១ ដល់ទី ៤ ចប់ . . | ,, | ១០៛០០ |
| រឿងព្រះមហោសថ ទី ១ . . . . . | ,, | ១០៛០០ |
| ,, ,, ទី ២ ទី ៣ . . . . | ,, | ៨៛០០ |

P.K. 18
1953

# រឿង

# នាងបំប៉ាហោង

ការផ្សាយរបស់

លេខ ៨៨ វិថីអែមេក្រង់ ភ្នំពេញ

ជិតពេទ៍កុន ព្រហ្មបាយ័ទពីខាងកើតផ្ទាល់

※ ※
※

រក្សាសិទ្ធិ

ព.ស. ២៤៩៦ — គ.ស. ១៩៥៣

# ឧបត្តិកថា

បញ្ហាហេតុដែលនាំឲ្យកើតសៀវភៅនាងចំប៉ាថោងនេះឡើង ដោយបណ្ណាគារខ្ញុំសរសេរបម្លងចេញពីសាស្ត្រាស្លឹករឹត ដែលបុព្វបុរសបាននិពន្ធទុកមកជាយូរសត្តវត្សណាស់ហើយ យកមកបោះពុម្ពផ្សាយចែកទុកជាសម្បត្តិមួយដ៏ប្រសើរដល់អ្នកត្រូវការអាន ការសរសេរបម្លងតាមច្បាប់ដើមនេះ ខ្ញុំបានកែពាក្យដែលគ្នាំងគ្នងខ្លះ ឲ្យរត់បទតាមសម្ពស្សរបស់កាព្យឃ្លោង ហើយនឹងកែអក្សរឲ្យបានត្រឹមត្រូវឡើងប៉ុណ្ណោះ

ហេតុនេះ ខ្ញុំសូមអភ័យទោសដល់លោក.អ្នក ដែលថ្នឹកខាងពាក្យកាព្យ បើឃើញថាពាក្យពុំសូវប្រពៃ ឬ គ្នាំងគ្នង យ៉ាងណា សូមលោកមេត្តាជួយពិនិត្យកែសម្រួលឲ្យខានផង ។

បណ្ណាគារ គីម-គី

# រឿងនាងបំប៉ាហោង

នេះបទកាកគតិ　　យើងខ្ញុំលើកលុត　　ជូញ្ញានបាទបទ
ក្រុញក្រាបវន្ទា　　ក្រោមល្អងធូលី　　តាំងក្បិបុប្ផា
បង្គំភគវា　　សារពេជជិនស្រី ។　　តោះតាំងព្រះធម៌
ប្រសើរបវរ　　បើកបទបាលី　　វែតហ៊ុនសែនពាន់
មានព្រះគម្ពីរ　　សោតសូមវន្ទី　　អញ្ជលីនរោ ។
បង្គំព្រះសង្ឃ　　ប្រសើរសិងទ្រង់　　សីលសុទ្ធសោភ្ដា
ទិនអង្គបង្គំ　　ប្រណាម្យសោភោ　　ព្រញុំប្រាណវន្ទា
ទុកលើសិរសា ។　　ដ្បិតខ្ញុំនឹងថ្លែង　　និទានចាប៉ែង
ជុំជាតិអតីតា　　កាលព្រះពុទ្ធអង្គ　　ប្រាស់ប្រាប់លោកា
គឺព្រះសម្មា　　សម្ពុទ្ធថ្លាថ្លៃ ។　　កាលទ្រង់នៅក្នុង
វដ្ដអន្ទុង　　សាគរជល្លៃសៃ　　ពុំទាន់ត្រាស់ស្រេច
សារពេជញាណញៃ　　បំពាក់នៅនៃ　　វដ្ដសង្សារស្មោះ ។
ចេញសាងបារមី　　ជាតិជាពោធិ　　សត្វសោតកាលនោះ
ភពកាន់រាក់វណ្ណ　　កំបាំងសូន្យសោះ　　ពីមុនមិញនោះ
ពហុជាតា ។　　មិនមាននគរ　　ថ្លាថ្លៃបវរ
រតនរាជសេមា　　រាស្ត្រផងកុះករ　　វីវរត្រៀបត្រា
សន្មត់នាមថា　　ពារាណសី ។　　ក្សត្រប្រិនមហិមា　　មូលមកវន្ទា
ព្រះបាទនរបតី　　ដោយនគរមាន　　សត្រូវយារយី

មកពីនបារមី　សម្តេចពជា ៗ　ក្បិនក្បែរយឯក
អង្គអគ្គវៃក　សិងនាំភក្ត្រា　ថ្វាត់ថ្វាយបង្គំ
ប្រណម្យក្សត្រា　សប់ទិនទេព　ពិតពុំដែលដាច់ ៗ
ខ្ទះនាំបុត្រ　ធោមឆាយពិសី　ល្អល្អះស្រស់ស្រប
ស្អិតស្អាងអាត្មា　របនាក្បូក្បាប់　ឡើងលែមរំលេច
សោតសិនសុវណ្ណា ៗ　ថ្វាយជាទាសី　ព្រះបាទភូមី
សន្ទុពជា　កំណាន់ខាន់ខាវ　ទាសីទាសា
មុខមន្ត្រីណា　រំពង់ណែនណាន់ ៗ　ព្រះអង្គមានអគ្គ
មហេសីវរល័ក្ខ　ប្រសើរសោភ័ណ្ឌ　ទន់ភ្ទន់បាតបប
កើតកបកំណាន់　កក្រុហាក់ព្រះចន្ទ　វែងចាំងភ្លឺថ្លា ៗ
ស្រីរតនបវរ　ទ្រង់ព្រះនាម្មករ　កែវសុទ្ធិស្នេហា
ចង្អស់ព្រះស្នំ　ឧត្តមសោភា　ជាស្ងើមអស់នា
គន្ធពាពណសី ៗ　ស្តេចសោយរាជស្កល់　ឯកឥតអំពល់
គ្រមកក្សន្តព្រះទ័យ　យូរលង់តិចទៅ　ចមទៅភូមី
នូវព្រះប្អូនស្រី　មិនដែលមានហ្មង ៗ　ជាហេតុអស្ចារ្យ
ក្បិណនាងទ្រង់គភ៌　បុត្ររតន៍ស្នេស្នង　ព្រះវរបិតា
ស្នេហាស្ងួនគ្រង　ស្តេចឲ្យអ្នកផង　ចោមចាំរក្សា ៗ
លុះដល់ ១០ ខែ　វស្សាទៀនទេ　បរិបូណ៌ហើយណា
នាងទីនប្រសូតិ　ពជបុត្រពំរ៉ា　ឆៀបឈឺទក៏

ទល់ទប់ពុំបាន ៗ ទើបទូលព្រះបាទ ព្រះបវរនាថ
ឥស្សរប្រធាន រៀមរើយប្អូនឈឺ ដម្កងប្រាណ
ប្រឹងប្រែងពុំបាន ញាប់ញ័រកាយា ៗ សមនឹងសម្រាល
បុត្រស្នងត្រកាល ប្រាកដនៅនា ថ្ងៃនេះមិនទេ
ឥតឯឃ្លាតឃ្លា សូមព្រះករុណា ប្រោសប្រាណប្រណី ៗ
ក្បិនក្បែតឥស្សរ ស្តេចស្តាប់បន្ទូល រន្ធត់ទេវី
ស្តេចវែងភ័យគិត ឯងឥតស្មារតី គនគិតប្រណី
ព្រះប្អូនពុំអារ ៗ ស្តេចឲ្យរត់រក ពេទ្យមិត្តមក
ចូលជួយរក្សា នៅចាំបំរើ ព្យាបាលរោគា
រួតរឹតកាយា សព្វសាប់សរសៃ ៗ តែងគស់ផ្តល់ផ្ទប់
ជម្ងឺលើសលប់ ឃ្លេងខ្លាំងនៃក្រែ ត្រជាក់ខ្លួនស្រឹម
ល្វឹងល្វើយល្ហិតល្ហៃ ស្មើបាត់ស្មារតី ពុំដឹងកាយា ៗ
ទើបស្តេចទ្រង់ត្រាស់ សេនារហ័ស ទៅហៅហោរា
ឲ្យមកប្រញាប់ គ្រាឥឡូវណា ហោបានដឹងការ
រត់ទៅម៉ម្មា ៗ ដល់ហើយក្សត្រា បើកបន្ទូលថា
អើហោព្រឹទ្ធា ចូរមើលស្រីរត្ន ឈឺពុំទាន់ជា
បើតាមតម្រា តើជម្ងឺអ្វី ៗ ទើបហោទាយថា
នាងប្រសូតិណា រាជបុត្រពិសី ឥឡូវនេះម្តង
រូបស្អប្រិមប្រិយ សូមព្រះចក្រី ទ្រង់ផ្គាប់ចិន្តា ៗ

ស្តេចសួរទៀតថៃ  ប្រសូតិនេះនៃ  តើគាបឬជា
ថ្ងៃនេះឬស្អែក  ឲ្យដឹងពេលា  មើលតាមតម្រា
ឲ្យប្រាកដជាក់ ៗ  ហោស្តាប់ព្រះសួរ  ស្រេចហើយគន់គូ
រកមើលគ្រោះថ្នាក់  ដឹងសព្វសេចក្តី  ទើបទូលទ្រង់លក្ខ
ថាមានជោគជាក់  គ្មានគ្រោះថ្នាក់អ្វី ៗ  ព្រះអង្គនឹងបាន
បុត្រកល្យាណ  នាយប់យាមបី  ប្រសូតិមកជាក់
គឺរាជបុត្រ  សូមព្រះបិត្រ  ជ្រាបក្នុងកាយ ៗ
បុត្រនេះល្អផ្ទែក  ហាទៀងបំប្លែក  មនុស្សក្នុងលោកី
នឹងមានបំប៉ារ  សុវណ្ណសោភី  ជុះបុះអំពី
ព្រះឧស្ដធិគា ៗ  តែថានឹងចាក់  បចេញផ្ទោះផ្ទាក់
ព្រាត់ព្រះមាតា  កំព្រាគោកយ៉ាក  លំបាកមហិមា
ដើរដោយមាគ៌ា  ត្រមោជឯកអង្គ ៗ  ទើបមានស្វាមី
រិទ្ធិសិរី  ចុំប៉េងតូចពង្ស  ជាក់ជាកំពូល
ឥស្សូរធោមយង់  ស្តែងស្តេចទ្រើសទ្រង់  ភជវិនវិទ្ធា ៗ
មូលមកបង្គំ  ព្របាទឧត្តម  ហាក់ដូចបិតា
មាតាបារមី  ដោយរិទ្ធិចេស្តា  គោះមនុស្សទេត្ត
យល់ហើយស្ងប់ស្ងៀង ៗ  ព្រះអង្គស្តេចស្តាប់  បន្ទូលពេញគាប់
ហោហើយអរឯង  អាចឲ្យយល់ច្បាស់  ទ្រង់បាត់ចំបែង
មាសប្រាក់គាត់តែង  ទ្រង់ព្រះរាជទាន ៗ  លង់លុះរាត្រី

វេលាយាមបី　ស្ងប់ស្ងាត់គង់ថាន　ទើបនាងប្រសូត
រាជបុត្រកល្យាណ　ត្រកាលក្រមាន　នៅនាលោកិយ ៗ
ដូចមាសនពគុណ　ផ្ទិនផ្កាត្បូងគន្ធ　ព្រះភក្ត្រប្រិមប្រិ
លើសលែងទេព្តា　នូវនាសួរស្រី　បែងបេះស្រដី
ពុំដូចអ្នកផង ៗ　កាលនាងទឹងហា　មានផ្កាចំប៉ារ
ធ្លាក់ចុះមកហោង　សិងសូវណ្ណា　សោភាឥតហ្មង
ក្លិនក្លែបល្អប់ល្អង　ហាក់សេគណា ៗ　កាយៗ ឈ្ងុយឈ្ងប់
ហាក់ដូចគេអប់　ទូទៅទិសា　ហើយនាងអង្វរ
ព្រះវរមាតា　សូមបែកចាយផា　បំណាយធ្វើទាន ៗ
ស្រេចហើយប្រែផ្សង　ត្រឡប់ក្នុងទឹង　បរចាពុំបាន
ទាំងពីរព្រះអង្គ　ស្តេចទ្រង់ក្រេមក្សាន្ត　ធ្វើបុណ្យឲ្យទាន
ចំរើនព្រះស្រី ៗ　ឲ្យលេងមហាស្រព　ណែនណាន់គ្រប់សព្វ
ប្រាំពីររាត្រី　ហើយថ្វាយព្រនាម　តាមដោយប៉ែត្តិ
ឲ្យហៅនាងស្រី　ចំប៉ាសុវណ្ណា ៗ　លុះចំរើនធំ
រូបរាងឧត្តម　ដូចរង្សព្រះចន្ទ　ព្រោងព្រាយប្រិមប្រិ
ស្រស់ស្រីសោភ័ន　ប្តូចព្រះឥន្ទ　ទាំងធកាម្ចា ៗ
ហើយនាងតែងទៅ　ប្រាសាទលំនៅ　ពីព្រះរាជា
ពិតពុំដែលដាច់　សព្វទិនទៅ　កាលនោះមានធ្លារ
មេមួយមានគភ៌ ៗ　ចូលមកសម្រាល　កើតកូនកណ្តាល

ពិនព្រះទ្រង់ធម៌ ច្រើនថ្ងៃធំផ្លូក ថ្កាសទ្រលុកល្អ
រាសទូទៅ ក្រោមប្រាង្គប្រាសាទ ៗ ជិតជើងជណ្ដើរ
ស្រីរត្នប្រសើរ ស្ដែងស្ដេចឃ្លាឃ្លាត ទៅគាល់បិតា
ថ្ងៃថ្វាននាង តាមហៃព្រះបាទ ជាប់ជាប្រក្រតី ៗ
ហាក់មានស្នេហា នឹងកងបិតា ប្រសើរសល់ស្រី
ប្រាសប្រាណរនៀល មមៀលឥន្ទ្រិយ ឧបបាទក្សត្រី
សុវណ្ណចំប៉ារ ៗ នាងអរថ្នាក់ថ្នម ត្រកងបីបម
ឡើងលើប្រាង្គប្រា សាទសំរេចឋាន ស្ថានសុវណ្ណ
ប្រាប់អស់បរិវា មេត្តាស្ងួនគ្រង ៗ នាងឲ្យរក្សា
ថែគ្រប់វេលា មិនឲ្យមានម៉ង ពានមាសពានប្រាក់
តែងដាក់ភោជនផង រាល់វេលាហោង សព្វទិនរាត្រី ៗ
រីឯកូនទ្វារ បែងបេះបរបា ប្រដៅស្រដី
បេះបប់កាសា ស្ដីថាអ៊ី ៗ ធ្វះធ្វើយឥតបី
ទើសទាក់ឡើយណា ៗ យើងនឹងស្រដី ដ្បិតមេកុំកៃ
មួយមានគតិណា គ្រប់ខែគ្រប់ថ្ងៃ ឈឺផ្ដួមហិមា
ឡើងពីផល្វសា មិញបានដល់គោក ៗ ទៅកាប់សំបុក
ប្រមូលរើសទុក ដំនោបក់ធ្លាក ពារឡើងពីងពួន
លាក់ខ្លួនសៀតសឹក សុដសោតហើមក ជាច្រើនមហិមា
ខ្លះខ្ទៅតំពរ អាប់អស់អន្ធករ អាកាសពេញមោ

ដោយនូវវិធី    គម្ពីរមោហា    ទ្រង់ទ្រើសបុស្សា
ជាសត្វតិរច្ឆាន ៗ    ស្រេចហើយគម្ពីរ    លាលះអំពី
សំបុកបុះថ្កាន    រកគៀនមិច្ឆា    ព៌សត្វស្ថាន
ហែបហែលដោយគៀន    នាទីគគ្គារ

## នេះបទពំនោល

វង្វេងហែមន្ទព្រានព្រៃ    ស្វះស្វែងព្រាព្រ័យ
ប្រយោជន៍បរបាញ់អម្រឹគា    ដើរសៀរប្រែបត្នោរផល្លសា
អគ្គឯងឯក្កា    រលះរលាំងដើរលុក ៗ
ដើរឈប់ស្តាប់ហើយតក្រុក    ខំភនខំរុក
សំកុកសំកាំងផ្អៀងផ្អង    ក្រែងពើបអំម្រឹគយង់យួង
បិត្តសោតប៉ុនបង    ប្រមាថសម្លាប់សន្យំ ៗ
ដើរដល់មន្ទល់ព្រៃធំ    ភិតភ័យបារម្ភណ៍
ភ៏គិតយ៉ាងខ្វាំងហើយថយ    កង់បិត្តគយគន់ក្រែងឆ្ងាយ
គេផងអាចឲ្យ    ក្សិណក្សយប្រល័យបាត់បង់ ៗ
ឈរឈានប្រុងប្រាណប្រនន់    ការបួលតម្រង់
សំដៅសំបុកក្រពើរ    យល់សុទ្ធប្រាកដនៅទើ
ព្រានគិតថាយើ    ស៊ុទ្ធអ៊ីធំល្អអំបាយ ៗ
មកនៅជិតប្តួឆ្ងាយ    អញយកទៅថ្វាយ

ព្រះបាទឥសូរសីរិសា　　　　សំបុានសម្បត្តិទ្រព្យ
ដូចអញព្រហ្មា　　　　ឬមិនកើតទេឡើយហោង ៗ
ព្រានគិតក្នុងចិត្តប៉ុនប៉ង　　　　សរសើលោកផង
លោកអញថ្ងៃនេះធំក្រៃ　　　　គុណព្រានបួលថ្កានវិសៃ
បីបានដាក់ដៃ　　　　លើស្មាស្រស់រូតរត់ ៗ
ព្រានឈ្លៀតសង្កាតប្រឹងប្រិត　　　　ដល់ដូចកំណត់
ហើយព្រាននាំចូលទៅថ្វាយ　　　　ប្រណាប្រែបលុតពីបម្លាយ
ក្រូចក្រាបក៏ការ　　　　បង្គុំប្រណម្យទូលថា ៗ
សូមទានខ្ញុំព្រះករុណា　　　　ថ្វាយស៊ូទកម្ម
សូមជ្រាបទូលល្អងធូលី　　　　គុណព្រះសន្ទុកដក្កូមី
យល់ស៊ូទកម្ម　　　　ស្តេចត្រេកអរឥតឧបមា ៗ
ត្រាកាលនឹងស៊ូទកម្មា　　　　ធំម្តេចមហិមា
ហើយទ្រង់ប្រទានរង្វាន់　　　　សំពត់អាវស្បៃសោភ័ណ
ព្រានបានរួសរាន់　　　　ថ្វាយបង្គំលាក្សត្រក្សាន ៗ
ស្តេចសព្វព្រះទ័យបំណាន　　　　ហើយព្រះរាជទាន
ឲ្យយកទៅថ្វាយបុត្រី　　　　នាងអរទិនអគ្គអញ្ជលី
ថ្វាយវរនុជ្ជ　　　　បង្គំទទួលយកហោង ៗ
ន្មាឃើញថាអេះអុកផង　　　　អស់នេះទង់ហោង
ចិញ្ចឹមក្រូតើនេះណា　　　　ខ្ញុំកខ្វល់កង្វល់ចិន្តា

យល់សុទ្ធកម្មា ជឿនដោយយោបល់មែនមាន ៗ
ហើយក្រាបទូលនាងកល្យាណា ចាបែននិទាន
ដំណើរទំនៀមទម្រមា បពិត្រពជធីតា
សូមទ្រង់មេត្តា យល់ខុសនៅច្បាប់បុរាណ ៗ
រៀនមកពិតពុំដែលមាន យកសុទ្ធតិរច្ឆាន
មកទុកបញ្ចឹមរក្សា ពុំដែលដឹងគុណអ្នកណា
ក្រែងមានភ័យា ដំនៀលដំណរតំក្រោយ ៗ
កាយបំបែកកាឲ្យហើយ ជីវិតនៅឡើយ
ថ្ងៃក្រោយនោះនាំកើតទុក្ខ អំពីនេះទៅឯមុខ
ក្រែងនៅតោតផុក ប្រាកដដូចពាក្យខ្ញុំថា ៗ
នាងស្ដាប់ពាក្យពីរឡា (១) ក្រោធក្រៃជេដ្ឋា
ម្ដេចកាជាសត្វតិរច្ឆាន ផ្ញើរបេះនាំឲ្យរំខាន
ជាមេកំពន់ រូបអ្នកនគាន់សោះសា ៗ
នាងបានរំពាត់ម៉្មា ដេញវាយវិឡា
ប្រព្រាតប្រព្រោងពីងពូន ដែលជ្រកពួនស៊ីកហោក់ខ្លួន
ភារៈភ័យមកជួន ស្រងំពិតពុំស្រដី

នេះបទកាកគតិ

ស្រស់ស្រីចំប៉ារ មានព្រះវាចា ឲ្យយកសំឡី

---

១ វិឡា គឺ ឈ្មោះកូនឆ្មា

មកហើយត្រសព្វ ទ្រាប់ពន់កុម្ភី ថ្នាក់ថ្នមឥតបី
ផ្ទួសប្រហែសការ ៗ រក្សាដល់ញាស់ ឈ្មោលធំឥតខ្ពស់
រកក្រពើណា មកប្រៀបពុំបាន នាងនាដថ្លៃថ្លា
សប់ព្រះទ័យា កូនកុម្ភីនោះ ៗ ពេកពន់ប្រមាណ
ហើយយកសុវណ្ណ ធ្វើដំណាក់ស្នោះ តាំងជារាជស្ថាន
ដាក់ក្រពើនោះ ក្បូរក្បាច់ថ្លាក់ផ្ទុះ នៃបនៅសូរ្យការណ៍ ៗ
ហើយទើបយកពេជ្រ ដាក់ដាំរលេច មរកដកែវមាន
ពីទូរទិម សែនសំបណាន រកផ្ទឹមពុំបាន
ភ្លឺផ្លេកព្រនាយ ៗ ជាន់បេះធ្វើល្អាន របនាដំនាន
ហើយនាំមកថ្វាយ សុវណ្ណបំប៉ារ ធីតាឆោមឆាយ
ត្រេកអរសប្បាយ ទទួលស្រពន់ ៗ ហើយដាក់ក្រពើ
ហែបហែលលេងលើ ស្ពានពេជ្រសោភាន់ អ្នករក្សា
សោតជាកំណាន ដល់ពេលមិនទាន់ ជូនអស់អាហារ ៗ
ល្អាងមាសល្អិនល្អៅ ១០ ហាតជំរៅ ប្រវែងនោះណា
១៩ ព្យាមពិត ច្បងដាំផ្លូវផា បីជាន់សស្រា
ភ្លឺផ្លេកព្រោងព្រាយ ៗ ក្រពើត្រេកអរ សោមនស្សសាទរ
ក្សេមក្សានសប្បាយ មិនយូរប៉ុន្មាន ប្រែចិត្តពាយអាយ
គិតកល់ឧបាយ បំបាត់គុណគេ ៗ ប៉ងទឹងភោគ្គា
នាងសុវណ្ណបំប៉ារ ជាមន្ត្រលើសីហ៍ ពុំដឹងគាត្នា

មានពៀបាបធ្ង ធ្លាក់ទៅទីរយ៉ើ សោយទុក្ខវេទនា ៗ
នាងបំប៉ារថោង គេទុកជាប្រង ស្មើពុទ្ធមាតា
សម្មាសម្ពុទ្ធ បានលុះសោគា ព្រះទ័យករុណា
ដោយពុទ្ធពួជពង្ស ៗ ស្រីគេទ៌ទត្តម ប្រឹមប្រិយសក្រសម
ទន់ភ្លន់ឥតគ្គង ព្រះភក្ត្រប៉ពាង ល្ហាសល្អន់វរង្ស
ល្មមល្មៃមានទ្រង់ ស្រគត់ស្រគុំ ៗ កាឡោះកុម្ភី
ទ្រើសទ្រង់រិទ្ធី សាហាវយង់ឃ្នង មិនមានមេត្តា
ករុណាប៉ុនល្អង ចិត្តកំបណង ប្រមាថក្បត្រ ៗ
យកជាអាហារ ហេតុចិត្តអនុពាល គិតបានអប្រី
ពល់ពេលវេលា ទាសាទាសី តែងជូនបំណើ
សប់ទិនទេវ៉ ៗ សម្រែកដួបផ្គ កក្រើកខ្លួខ្លួ
លុះលាន់មាត់ថា ប្រសិនបាននាង សុវណ្ណចំប៉ារ
ធ្វើជាអាហារ នៃអញឥឡូវ ៗ សំអញទាញមាត់
ស្មើបានសម្បត្តិ សួរសោតនិតនៅ ស្ថានត្រៃត្រិង្ស
ឥតគណនាគួរ គិតហើយរង់ត្រូវ បង់បរិកេត្តា ៗ យកមកបន្តាំង
ទុកតែក្នុងភង ក្នុងល្អាងបេះណា ហាក់ដួបមានទោស
មិនមានករុណា បេញបរយាត្រា ទៅទៀតពុំបាន ៗ
ពីនេះទៅណា អញទឹងគោត្តា ក្រស្តូផងសព្វស្ថាន
មិនតែប៉ុណ្ណោះ តាំងនាងកល្យាណ សុំឲ្យខាងបាន

ដូចចិត្តអញប៉ង ៗ ពេលនោះទាសី ឮពាក្យកុម្ភី
តែវិលវិញផ្គង លុះដល់ប្រាសាទ នាងនាថប្រះប្រង
ទូលតាមទំនង ពាក្យពីក្រពើ ៗ ខ្ញុំម្ចាស់សូមក្រាប
ទូលឲ្យបានជ្រាប អំពីដំណើ ក្រពើតិរច្ឆាន
ចិត្តវាសើរើ មើលងាយឥតបើ គោតក្រែងសោះសា ៗ
ចិត្តវាគុំគួន បរិភោគឥតសួន ព្រះអង្គឯងណា
ទោះទាំងយើងខ្ញុំ នឹងរាស្ត្រប្រជា ពិតពុំមេត្តា
មោហាកន្ទង ៗ ស្រីរតន៍ប្រសើរ ដឹងដោយដំណើរ
ទាសីនោះហាង នាងបើកព្រះឱស្ឋ បន្ទូលវិងស្នង
កុំស្រដីបង ឲ្យលេចឮដល់ ៗ ព្រះវរបិតា
ទ្រង់ព្រះក្រោធា នាំកើតកង្វល់ នឹងឲ្យសម្លាប់
បាត់សព្វខានយល់ អញអាសូរសល់ បានជារក្សា ៗ
កំមេគិតក្រែង ពាក្យពីរថ្លែង ម្តេចៗក្តីណា
តើខឹងក្តៅអ្វី តាមតែវាថា នាងកុំបរហា
កុំទៅទៀតឡើយ ៗ ឯនាងទាសី ស្តែងស្តាប់សិដី
បំប៉ារថោនហើយ ប្រណម្យក្រាបខ្លួន ពុំអាចនៅឡើយ ភ័យភិតពុំស្បើយ
ម៉ែៗមហិមា ៗ លួចលបទៅទូល ព្រះបាទឥស្សូរ
សន្ទុរភាជថ្លៃថ្លា សូមទានព្រះអង្គ ស្តេចទ្រង់ករុណា
ទូលបង្គំជា ខ្ញុំកាលនេះម្តង ៗ ឥឡូវក្រពើ

ចិត្តគាប់សើរើ ក្រោធក្រៃគន្ធ ក៏ទឹងបរិភោគ
ស្រីចំប៉ាវថោង នូវអស់ព្រស្ដផង ឲ្យក្ស័យជន្មា ៗ
ខិនពួនកំបាំង ថានាងបង្ខាំង ធ្វើទោសនៃក
សូមទានបើទុក នៅទៅយល់ជា កើតទុក្ខភ័យា
គឺច្បាស់ជាមាន ៗ ស្ដេចស្ដាប់សៅដៃ ទូលទើបក្សត្រថ្ងៃ
ធុញថប់កន្ទុំប្រាណ ស្ដេចទ្រង់ខ្វាល់ខ្វាំង ហើយបន្ទូលថ្កាន
យីអាតិវង្វាន ហ៊ានណាស់នាងអើយ ៗ ពុំដឹងខុសគាប់
វិលវឹងត្រឡប់ ទឹងសុំព្រងើយ បើច្នោះនាំគ្នា
សម្លាប់ឲ្យហើយ ទុកព៏ថ្វីឡើយ អាចោរសាម៉ាន ៗ
កាលនោះអាមាត្យ បង្គំព្រះបាទ រូតរត់ទៅថ្កាន
ទូលពងទេវី ក្សត្រីកល្យាណ បពិទសូមទាន
ព្រះពងធីតា ៗ ដូរិតព្រះភូមិ ននាថនរបតី
ព្រះជីនកក្សត្រា មានព្រះតម្រាស ត្រាស់លើសវិសា
ប្រើខ្ញុំព្រះករុណា ឥឡូវទេះម្ដង ៗ ឲ្យយកក្រពើ
កន្ទុល្អាន់ប្រសើ ទៅពីឃាដបង់ ដូរិតក្រពើព
មហាមាទ្រើសឃ្វង ចិត្តចោរប៉ុនប៉ង ប្រមាថព្រះរាជ្ញ ៗ
ចំប៉ាវស្រីថ្ងៃ លុះត្រូសម័យ ដូច្នោះហើយទ្រង់
ចិន្តារតន់គិត អាណិតកន្ទង កណ្ដោចឯអង្គ
រលោងនេត្រា ៗ ទអាសូរក្ដាត់ ធ្លាប់នៅស្នេស្និទ្ធ

ល្អងមាសមាណា កបដោយចំណី គ្រាកាលពិសារ
ទឹកសរវង់ថ្វា ធ្លាប់នៅប្រក្រតី ។ ឥឡូវម្តេចប្រែ
ព្រាត់ប្រាសខុសគេ ដល់ដាច់ជីវិ រីឯល្អងនោះ
ដាក់ដាំតែរមនី ដំណារនៅទី អាសាទេហោង ។
ហើយនាងចំប៉ារ បើកបន្ទូលថា ហៃបងអើយបង
បើមានមេត្តា ករុណានេះម្តង តាមចិត្តបងប៉ង
ទ្រព្យអ្វីក្តីណា ។ អញ្ចេះសាតក៏ឲ្យ រង្វាន់តាមដោយ
ចិត្តបងប្រាថ្នា ដ្បិតបានចិញ្ចឹម ព្រួយប្រាណរក្សា
ពីកាលនៅជា ពងឡើយបងអើយ ។ សូមបងយកទៅ
លែងក្នុងទឹកជ្រៅ ឲ្យសៀមគន្តើយ ហើយទូលបិតា
ក្សត្រាត្រាណត្រើយ ថាសម្លាប់ហើយ ដូចព្រះរាជា ។
ឯអស់មន្ត្រី ជូនអញ្ជលី វរពជផិតា
តាមតែព្រះអង្គ ទ្រើសទ្រង់ករុណា ឥតបើទឹងថា
អ្វីឡើយក្សត្រី ។ នាងស្តាប់ហើយអរ ពាសពេញអំណរ
ទឹងអស់សេនី ដោយមានអនុកូល តាសូរកម្មី
នោះនាងអរក្រៃ ស្រែចហើយសេនា ។ ថ្វាត់ថ្វាយបង្គំ
លាចរចុះចំ ល្អងដាក់កុម្ភា ហើយនាំយកទៅ
សំដៅជលសា ដល់ហើយមច្ឆា លែងត្រីពីថ្កាន ។
ត្រីតើបតែជ្រឹ រួចចេញពីភ័យ

ហក់ហែលប្រាស់ប្រាណ បណ្តែតរូបរង ស្ទឹមស្ទង់ក្លាហាន
ហក់គោះកើតមាន កណ្តាលផល្លូសា ៗ ហើយហែលចូលមក
ពោលពាក្យបោះបោក ប្រាប់អស់សេនា ថាហៃមន្ត្រី
នាងស្រីបំបារ គេនូវស្ថានណា នេះម្តងឥឡូវ ៗ
ចូលអស់សេនា ក្រាបទូលក្សត្រា ផិតផះចាមចៅ
ឲ្យធ្វើគារវៈ បំបារស្រីពៅ អញ្ចឹងនាំទៅ
ធ្វើជាអាហារ ៗ កាលនោះមន្ត្រី ស្តាប់ពាក្យកុម្ភី
គ្រេវគ្រោធមហិមា ថាចគ្រតើរ តិរត្ថ៍ឫស្សា តែមិនបរទា
ពោលពាក្យទ្រគោះ ៗ អ្នកមាគុនណាគាប់ ម្តេចក៏ត្រឡប់
ប្រមាថវិញច្នោះ នាងយកតីស្លាប់ ឥតសព្វសូនសោះ
នាងសូមលាលោះ ជីវិតរួចបាន ៗ បំភ្លេចព្រះគុណ
វិសេសមហាធ្ងន់ ធ្ងន់ពន់ប្រមាណ ទុកស្មើមាតា
បិតាប្រធាន ដែលអ្នកណាហ៊ាន ជស់លែងបេះនៃ ៗ
ហើយទើបសេនា រឹងប្អានគ្រោះហ៊ា លំនៅទីទៃ
សំងំស្ងៀមស្ងាត់ បាត់ឥតសង្ស័យ ក្រែងមហាក្សត្រថ្លៃ
ជ្រាបសេចក្តីផង ៗ កាល្ហោះក្សត្រី ប្រសើរលើសស្រី
នាងបំបារថោង ព្រួយព្រះហឫទ័យ ស្រីថ្លៃក្តាត់ហោង
សោយសោកសៅហ្មង ក្រៀមក្រមក្រ្លា និកថាទិសត្វ
គ្រពីសំព្រាត់ ទៅតែឯកា ម្ល៉េះសំទឹងបាត់

សូនស្ងាត់ឯងណា  រាប់ថ្ងៃរាប់ថ្ងា  សមពុំបានយល់
ទាំងនេះហេតុចិត្ត  ក្រពេទ្រើសក្តាត់  កាចក្រៃកំហល់
ពុំដឹងបាបបុណ្យ  ទឹងគុណពុំយល់  ធ្វើឲ្យអំពល់
អំពើថ្ងោះថ្ងាយ ៗ  អញ្ញាសោតស្ដីម្ដាយ  បានសុខសប្បាយ
ពីព្រោះអញឲ្យ  ម្ដេចឡើយចិត្តធំ  ខឹងខំដាលដោយ
ពោលពើពាក្យឲ្យ  មន្ទិលថ្នាំងថ្នាក់ ៗ  សមទឹងធ្លាក់ទៅ
នរកជ្រិះជ្រៅ  វែងវែងលំបាក  ពុំរួចវិលវឹង
កេងកោងបំពាក់  ដូចគេស្រះថ្នាក់  នោះទឹងវេទនា ៗ
នាងគិតខ្លោះហើយ  ក្សត្រិត្រានត្រើយ  ព្រះទ័យករុណា
ហើយនាងប្រើប្រាប់  ទៅជូនទឹងតា  ឲ្យយកគោផនា
ទៅឲ្យក្រពើ ៗ  យាយតាស្ដាប់ពប់  ឱនកាយគោរព
រួសរាន់ដំណើរ  រៀបចំអាហារ  តាមធិតាប្រើ
សាច់សប់សារពើ  ឥតមានខ្វះអ្វី ៗ  ហើយទូលទៅដល់
នៅនាមទួល  កំពង់ពារី  ស្រេចទើបស្រែកហៅ
អើហៅកុម្ភី  អញ្ជើញមកពី  សាសាច់ទាំងឡាយ ៗ
សាច់ធ្អិនសាច់ឆៅ  សាច់គោទាំងក្លៅ  សាច់ប្រើសសាច់ទ្រាយ
ជ្រូកក្ដាន់មាន់ទា  ទទេរងទន្សាយ  ពិសាសប្បាយ
មានគ្រប់ហៅណា ៗ  ក្រពើអប្បលក្ស  លុះស្ដាប់ពុំដាក់
ពាក្យជូនពាក្យតា  ស្ទុះមកត្រាំង ៗ  អរឯងក្ដាត់ណា

ទទួលអាហារ ពីគ្មានសល់នៅ ៗ ឯជូនទីងតា
ជូនសប់វេលា គ្មានខានទិតនៅ ក្រពើរង្គជាតិ
ជំក្កាត់ឃោឃៅ ដុះស្វះរៀវខ្មៅ អស់អង្គរូបា ៗ
វិធីធំបំឡែក ក្រៀវក្លាអនេក សាហាវមហិមា
តែងតាមធ្វើកល់ នៃអ្នកនាក អស់ឈ្ងញគេត្រា
នៅនាដល្វៃស

## នេះបទពំនោល

កាលនោះក្រពើពាលា ផាលដេញនាក
លលីលលើឈៀងធាប ប៉ុនប៉ងបំណាងពិឃាដ
ខិតខំសង្វាត ប្រយោជន៍ឲ្យផ្អែតអាត្មា ៗ
ស្ទាញស្ទុះហាក់ហោះព្យោមា ដោយរិទ្ធីអាត្មា
ប្រដេញប្រដំខំក្រៃ ហើយអ្នកនាកកិតភ័យ
ទន់ជើងទន់ដៃ ស្ទើតស្ទាំងកាទកាំងតក់ស្លុត ៗ
បើកទាន់ហើយចំហុត ប្ដោះប្ដាកប្រាកដ
ខ្ចរខ្ចប់នាកនោះណា រយ៉ែករយាករសោះសា
លិដលង់នាក មនុស្សម្នាសិងតែភ្ញាក់ផ្អាក់ ៗ
ហើយកហោលោតត្របាក់ ពាពាំធីផាក់
អស់អ្នកនគរក្នុងក្រៅ ញាប់ញ័រកិតភ័យក្ដាត់ក្ដៅ
ស្ងួសន្ធូសោកសៅ រំដើបរំជួលគ្រប់គ្នា ៗ

ពុំហ៊ានទៅកាន់ផល្លូសា ខ្លាចដល់មរណា

ខ្លួនពេកពន់ទីទៃ ទោះអម្រឹតនៅនាទីព្រៃ

ខ្លាចខ្លួននោះក្ស័យ ពុំអាចនឹងចុះផឹកទឹក ៗ

គុម្ពរិទ្វីពទ្វីក ផ្អកផ្អើលដូចសក

សត្វព្រៃគ្រប់ទិសពាធា ទោះស្លឹងបឹងព្រៃកគគ្គារ

សត្វស្វានទានា ស្ងប់ស្ងាត់ពេកក្តាត់សត្វថ្ងៃ ៗ

សឹងស្លាប់នៅកណ្តាប់ដៃ ប្រិនពន់ពេកក្រៃ

រកអ្វីប្រៀបគ្នានឡើយណា កាលនោះរីជូននឹងតា

ចរចុះនាក់ លក់ចំណិញផាប្រក្រតី

តើបពះប្រទះកុម្ភី អរឲ្យបំណើ

កឹស្មានផាដូចសត្វដង ៗ ក្រពើមោហាយឃ្នង

ស្រែកសត្វំពង ថាពៅនែជូននឹងតា

ចូលវិលទៅទូលក្សត្រា សូមនាងចំប៉ារ

សុវណ្ណនោះនាមកហោង ៗ បើពុំឲ្យដូចបំណង

ឯអស់ព្រស្តផង នឹងសូនកន្ទ្រព្រះនគរ

យើងឡើងទៅពិឃាដមរណៈ កោលាហលរ

ព្រោះជឿតអញតែងរក្សា ៗ កាលនោះយាយនឹងតា

គិតភ័យអស្ចារ្យ រលះរលាំងស្ងួតរត់

ដើម្បីទៅទូលបម្ដុ ដង្ហើមស្ទើផុត

ផ្ដិតផ្ដុតស្ទិតស្ទក់ក្អែកសរ ៗ មុខជាំមាត់ធ្លាក់ប្រែហា
អួលអន់ដើមករ ផ្ទឹកៗផ្អក់ហៀបក្ស័យ
រត់ចូលក្នុងរាំងក្សត្រថ្លៃ ទូលញ័រដើមដៃ
ស្រពោនស្រពាប់សស់សា ប្រណម្យហើយទំទូលថា
បពិត្រព្រះមហា ក្សត្រថ្លៃឥស្សរឥតស្មើ
សូមទានឥឡូវក្រពើ ដែលត្រាស់ឲ្យធ្វើ
កន្លងកាលពីមុនណា ៗ ឥឡូវនៅឯគង្គារ
ពុំក្ស័យជន្មា ស្រហាស្រហាវកន្ទង
បំបាត់ជីវិតមនុស្សផង ពុំដែលរំលង
រួចពីសេចក្ដីស្លាប់ណា ៗ អស់កស្ត្រស្រុកស្រែចំការ
ឈ្មួញសត្វនាវា សឹងស្លាប់រង្គាលសត្វស្ពាន
ឥឡូវបំរើតរប្ជាន ក្រាបទូលឲ្យបាន
ជ្រាបក្នុងព្រះរាជហឫទ័យ ៗ ឲ្យជូនចំប៉ារថោងថ្លៃ
បើពុំដោះនៃ នឹងរខូចក្នុងពារាណសី
នឹងពិឃាដពស្ត្របុរី ក្សិណក្ស័យឥតបី
សែសសល់សំណល់ឡើយណា ៗ ការល្មោះសន្ទុកជា
ស្ដេចស្ដាប់ជូនតា ហើយទ្រង់ក្រេវក្រោធខ្លាំងក្រៃ
រន្ធត់តាំងព្រះហឫទ័យ ដូចភ្លើងវិស័យ
ឆេះធ្លូលរំជួលក្ដៅក្ដាត់ ៗ ព្រះស្វរៈបន្ទូលវិញថ្វាត់

អញស្មានថាបាត់
ឥឡូវម្តេចថានៅឡើយ
ហើយវិលមកធ្វើទោសា ៗ
ដែលព្រះរាជា
មកហើយព្រះភុទបក្រិ
ត្រាកាលអង្គអញប្រើហាប់
សម្លាប់មែនហើយឬនៅ
ចូរឆ្លើយតាមត្រូវ
អាមាត្យក្រញូញក្រាបផ្ញួញជិត
រន្ធត់បំប្រប់អាត្មា
បពិត្រព្រះមហា
កាលនោះខ្ញុំប៉ងឲ្យក្សយ៉
គឺនាងសុវណ្ណចំប៉ា
ត្រាស់បន្ទូលថា
ក្រែងលោកើតវិកជូន
ចំណាងចំណាំកម្មកាយ ៗ
ប្រើខ្ញុំតាំងឡាយ
ហើយបានប្រទានសុវណ្ណា
រង្វាន់នៃយើងខ្ញុំផង ៗ

ដំរិតលែងមកទៀតហើយ
រស់នៅព្រដើយ
ក្សិណត្រាស់ឲ្យហៅសេនា
ប្រើឲ្យសម្លាប់កុម្ភី
បន្ទូលត្រាស់ខ្ញុំដំណើរក្រពើប្រញាប់ ៗ
អានាំទៅឆាប់
កុំកុហកមុសាក្បូវ
ស្រដីដោយនៅពាក្យពិត ៗ
ភាន់ភាំងភ័យភិត
ខំតែទូលតាំងភ័យា
ក្សត្រថ្លៃប្រសើរថ្កើងក្រៃ ៗ
ប៉ុន្តែស្រីថ្លៃ
នាងមានព្រះទ័យមេត្តា
ដើម្បីប្រយោជន៍យកបុណ្យ ៗ
មានបាបពេកពន់
ហើយក្សត្រិរតន៍ផេះមឆាយ
នាំទៅលែងក្នុងគង្គារ
ពាន់មួយជាក់ជា
ស្តេចស្តាប់ក្រេវក្រោធគន្ធង

នឹងបុត្រស្នែស្នង បន្ទូលបន្ទោសណាស់ណា
ខ្ញាល់នឹងមន្ត្រីយោធា ពុំខ្លាចអាជ្ញា
អម្ចាស់ឥស្សរប្រើប្រាណ ។ តាមដោយនាងនាថកល្យាណ
ម្នោះក្ររមកហ៊ាន ពកំងឃាត់ឃាំងអាជ្ញា
ឥឡូវគោងធ្វើម្នេះណា រកមនុស្សហានក្លា
ហោមបាក់ក្រពើពាល ។ បើឃើញតម្រង់តែក្បាល
ឲ្យបំកណ្ដាលប្រជុំទើបវាយរណា មិនទាស់តែនឹងអាត្មា
ទោះញាតិការ ប៉ុន្មានសិង ស្លាប់ព្រមផង ។
អាមាត្យស្លាប់ព្រះបង្រះបង្រង លាវិលវិងផ្គង
ទៅដល់លំនៅអាត្មា រើសរកអ្នកហ៊ានក្លៀវក្លា
បេះសិលសត្រា . ជំនាញល្អមទឹងទុកបំត្រ ។
រួបវេញខ្សែមូលមាំស្អិត ស្នរប្បកប្រើនក្ដាត់
លំពែងផ្ទួសាប្រេងប្រាង ប្រង់ប្រាណរួសរាន់តួងគាង
មាន់ទារធ្វើក្ដាង ប្រដាប់ប្រញាប់គ្រប់គ្នា ។
ស្រែបបរចុះទៅដល្វសា ជិះលើនាវ
លឿនវើនប្រុងចាំបាក់ ខ្វះស្បូត្រអាគុមសិទ្ធិសក្ដិ
ស្ពូរស្ដីប្រតីយក្ស ហាបោក្រពើយង់យ្នង ។
ខ្វះយកគារមាន់ចោមចង កាដិកាន់មូលផង
ងរៀបជាជួរចាំបោះ កើតកោលាហលកាលនោះ

ផ្អូកផ្អើលដេផាស　　មកដោយមើលក្រពើកាច ៗ
ក្រពើពុំភ្ញាក់ផ្អើលខ្លាច　　នាទូវអំណាច
តិចតួចដល់ប៉ុនកេស្បៀ　　អឹងអាប់ខ្មាន់ខ្មាប់ដល្ងធី
ស្បូរសព្វខ្លាំងក្រៃ　　គក្រើកកំពើគមហិមា ៗ
ក្បិណនោះក្រពើពាលា　　ផ្ទុះពីគគ្គារ
ត្របោមត្របាក់គាគោះ　　ផ្ទុះធ្លាយខ្ទាត់ខ្ទាយទូកនោះ
បែកបាក់សូន្យសោះ　　សន្ទឹកសន្ទាប់ពណាពយ៍ ៗ
ផ្អើលផ្អូកក្អឹកក្អូកព្រោនព្រាយ　　ស្ទុះលោតប្រញាយ
ប្រញាប់ឲ្យរួចពីកៃ　　រុំផ្លូវដែនផល្វសៃ
ដោលគ្រឿនពីដៃ　　លេះលាំងទៀនគោក ៗ
មារមួលកន្ទួលស្នប្រក　　ដោលពយគ្រប់ទូក
ប្រពាក់ប្រពូនលើគ្នា　　ខ្វះរស់ខ្វះស្លាប់ត្រៀបត្រា
ក្រពើនោះណា　　បរិភោគត្រអាលស្កប់ស្កល់ ៗ
ហើយស្រែកសម្រែកខ្លាំងសល់　　ថារើយពួកពល
នៅអស់មន្ត្រីសេនា　　យើងចង់ជូននាងចំប៉ារ
មកហើយអស់គ្នា　　ទីងរបាំលេងក្តីមរណ៍ ៗ
បើពុំជូនហើយអន្តរ　　ឆានចាំងឧគរ
ពុំរួចពីមាត់អញណា　　ទុកប៉ុនាងស្រីចំប៉ារ
នៅកើតទោសា　　បំណាងបំនៀររវែងឆ្ងាយ ៗ

ព្រស្តផង ស្ទាប់ថ្ពាត់ខ្ទាត់ខ្វាយ      ផ្ទៃក្រោមអន្តរាយ
ប្រាកដមិនមានមុសា      ជាហើយអ្នកទាំងអស់គ្នា
ចូរទូលក្សត្រា      ឲ្យនាំនាងនាថវរវង្ស ។
កំបីយឺតយូរនឹង      គិតគុំមង្អឹង
ឆាប់ៗ ដូចពាក្យអញថា      ទើបរួចរស់ជន្ម៉ា
ទៅទូលពជា      ដោយទូវដំណើរគិតភ័យ ។

## នេះបទកាកគតិ

ទូលបង្គំគ្រប់ប្រាណ      ក្រាបទូលឲ្យបាន      ជ្រាបល្អន់ផ្ទូល
ឥឡូវក្រពើ      មហិមារិទ្ធី      សាហាវឥតបី
ធ្មមស្មើបេស្តា ។      ចូលទោមជុំជិត      ប្រូនប្រានប្រកិត
បង្អៀតដល្វសា      ស្រាប់តែក្រពើ      ផុះពីគង្គារ
បោកវែកនាវ      លង់លិចខ្ទាត់ខ្ទាយ ។      លោតស្ទាចឹងខាំ
ត្របាក់ពារពាំ      គ្នាផងទាំងឡាយ      វិនាសមរណៈ
គព្រោលព្រានព្រាយ      រត់ឡើងប្រញាយ      ហោលគ្រឿងគ្រប់ដៃ ។
ហើយក៏ផ្តាំថា      ឲ្យទូលព្រះមហា      ក្សត្រក្សត្រាដៀសជ័យ
ឲ្យជូនពុំធារ      ចំប៉ារបោនថ្ងៃ      ទើបរួចពីភ័យ
មិនមានមរណា ។      បើពុំដូច្នោះ      នឹងក្ស័យសូន្យសោះ
ព្រស្តុកង់សេមា      ទាំងព្រះភូធរ      មហេសីក្តណា

មិនមានឃ្លាតឃ្លា ឡើយព្រះបក្រី ៗ ស្តេចទ្រង់សណ្តាប់
សេចក្តីសព្វគ្រប់ ពាក្យពីកុម្ភី ហើយស្តេចគន់គិត
អាណិតបុត្រី ចំប៉ារសុវណ្ណី ស្មើថ្មីមទ័យា ៗ
ហើយព្រះបមបៅ ស្តេចត្រាស់ឲ្យទៅ អញ្ជើញធិតា
មកដល់ពុំលង់ ស្តេចទ្រង់សោក្កា បើកបន្ទូលថា
ហៃសូនឪពុក ៗ ឥឡូវបិតា ព្រួយព្រះទ័យា
សង្រែងរង់ទុក្ខ ស្មើនឹងក្បិណកៃ្យ មែៗពុំសុខ
ផ្សិតសូនឪពុក ប្រយោជន៍យកបុណ្យ ៗ នេះម្តងក្រពើ
រូបរស់ប្រែប្រើ ធ្វើធ្វើល្មើសគុណ ហើយធ្វើពុតពាល
បណ្តាលទោសធ្ងន់ មនុស្សម្នាមហាជន ខឹងខាំគោត្តា ៗ
កើតក្តៅក្រហាយ កន្ទ៍នគរកាយ ទូរន្តទូប
កាលបើចុះទឹក ដើរដោយដល្ងសា ក្រពើមោហា
យាយីគ្រប់ប្រាណ ៗ គោះតាំងសេនា ដែលព្រះបិតា
ប្រើទៅប៉ុន្មាន សិងបាញ់ដែក រកាគ្រប់ប្រាណ
ក្រពើតិរច្ឆាន បរិភោគព្រងើយ ៗ ហើយផ្តាំថា
ឲ្យជូនចំប៉ារ សុវណ្ណជាត្រើយ ហេតុនេះឪពុក
ចល់ទុក្ខពុំស្បើយ សូនឪពុកអើយ គិតម្តេចនេះម្តង ៗ
ការល្ហោះក្បត្រ តែនពជទេវី នាងចំប៉ារថោង
ក្រាបក្រោមបាទា បិតាហើយហោង សោយសោកកន្លង

ទូញទូលទៅថា ៗ បពិត្រព្រះអង្គ វិសេសសូមទ្រង់
ព្រះរាជករុណា បើព្រះប្រទាន នឹងមានមេត្តា
សុំខ្ញុំករុណា រួចរស់រំលង ៗ អស់រាស្ត្រទ្រង់ស្តាយ
ផនបទទាំងឡាយ លើសបុត្រស្នូស្នង មិនឲ្យកូនជា
រក្សានេះម្តង ចុះអស់រាស្ត្រផង ពេញទាំងសេមា ៗ
ពុំគួរនៅខ្ចាប ក្រពើរកំណាច ទ្រង់ទ្រើសបុស្សា
កូនកើតតែមួយ ជាទ្រូយទ័យា ខុសធ្ងន់ក្តីណា
សូមប្រោសប្រណី ៗ ព្រះវរបិតា ស្តាប់នាងចំប៉ារ
ទូលអស់សេចក្តី ស្តេចវង់អាណាត បុត្រតេន៍ពិសី
ឱនឱបអង្គស្រី ថ្នាក់ថ្នមបរបា ៗ ហៃបុត្រព្រលឹង
កុំមាសមេទឹង ទឹងព្រះបិតា ទាំងនេះហេតុកម្ម
ចង់ចាំវេក ទើបយើងឃ្លាតឃ្លា ពីទូរវនទសល់ ៗ
ស្តេចសោយសោកខ្លាំង ស្មារតីភាន់កាំង នឹងនាងនិមល់
វង្វេងស្មារតី ឥតបីទប់ទល់ ប្រោសប្រាជាលដល់
សន្ទូបឈឹងនៅ ៗ ពេលនោះទាសី យល់ព្រះនរបតី
មីមាទៅហៅ ទៅទូលជ័យា ថ្ងៃថ្ងាស្រណៅ
កាយកប់ទូលទៅ ពីព្រះរាជា ៗ ការឈ្មោះក្សត្រី
ព្រះអគ្គមហេសី កែវសុទ្ធិស្នេហា គិតភ័យហៅហៅ
រត់ទៅមីមា ឱបព្រះបាទា ពិលាពទួញយំ

ហើយយកគគ្គារ ត្បិតព្រះកត្រា ក្សត្រថ្ងៃឧត្តម
ទាំងពជបុត្រ ប្រឹមប្រិយ៍ស្នួរសម ភ្ញាភ្ញាក់ហើយយំ
ទាំងបីអង្គា ៗ ហើយទើបក្សត្រី លើកហត្ថវន្ទី
ព្រះរៀមពជា ហេតុអ្វីស្តេចសោក អាម៉ោគមហិមា
ដល់ដួបប្អះណា ប្រាយប្រាប់ខ្ញុំផង ៗ រីកាលនោះណា
ព្រះរៀមពជា បន្ទូលវិញស្នង ហៃប្អូនត្រកាល
សង្ក្រាត់តត្តង ចូរពៅស្តាប់បង ដោយដំណើរណា ៗ
ប្អូនអើយក្រពើ ទ្រើសទ្រុះឥតបើ កុំបាបៈមាហោ
ផ្ដាំមកឲ្យជូន កូនស្ងួនពុំផ្ការ រាបរកោត្ដា
គង់ក្រាឥឡូវ ៗ ថាបើមិនឲ្យ នាងនាថតាមដោយ
ចិត្តរាឡើងទៅ រាសីងហឹង្សា មនុស្សម្នាគង់ក្រៅ
បងទឹងប្អូនពៅ រួមជាមួយគ្នា ៗ ហេតុនេះអញបង
ថប់ក្រៃកន្ទួង ទឹងនាងបំប៉ារ កូនស្រីតែមួយ
ជាត្រួយបិតា ទឹងឲ្យទៅជា បំណក់ក្តី ៗ
នាងស្តាប់ព្រះបង ស្រីស្រស់ទួនល្អង ប្រាបអស់សេចក្តី
នាងទូលព្រះបាទ ននាថស្វាមី បពិខបក្រី
ឥស្សូរប្រសើរ ៗ យើងម្តេចទឹងឲ្យ កូនទៅតាមដោយ
ពាក្យពីក្រពើ ស្រឡាញ់មន្ត្រី សេនីប្រសើរ
ប្តូរស្ត្រីនោះតើ ចោលបុត្របងហោង ៗ ពលអាខាកីទី

ស្រុកមួយស្រុកពីរ ច្រើនក្រៃកន្លង ទុកធ្វើអ្វីនោះ
មិនឲ្យទៅស្នង នាងបំប៉ារជោង ជាបុត្រពុំងារ ។
ពេលនោះអាមាត្យ ចូរទូលព្រះបាទ ច្រើនជងច្រើនគ្រា
បពិត្រសូមស្ដេច ឲ្យនាងបំប៉ារ ជូនទៅឆាប់ពា៉
ផ្ចិតការង់ចាំ ។ ក្សត្រាធិបតី ព្ញាក្យមន្ត្រី
ទូលទឿនស្រាំ តំងក្នុងចក៏ នេត្រារហាម
ព្រះក្រូដាំដាំ ក្ដៅក្ដាត់ៈពេកក្រៃ ។ សោកព្រះរាជបុត្រ
ថ្ងើមថ្ងៃវន្ទត់ ផេងផោងល្ហិតល្ហៃ ទុក្ខទល់ក្នុងប្រាណ
អួលអន់ស្ទើក្ស័យ ហោកប្រាសប្រាណក្រៃ ពុំចេញបរោ ។
ឯព្រះជីទី សិងសោយសោកក៏ លាបលន់ក្ដាត់ណា
ដល់ដួលសន្ធប់ ចំប្រែបកាយា ទាំងបអគ្គា
នូវលើមន្ទី ។ លុះលង់ភ្ញាក់ភ្ញាក់ ជឹងស្មារតីជាក់
ហៅហោព្រឹទ្ធី ក្រាបទូលព្រះបាទ ឧទាថសួរស្ដី
អម្ចាស់សិរសី យើងនូវនេះណា ។ បពិត្រសូមទាន
ព្រះទ័យក្រៀមក្សាន ស្ដាប់ខ្ញុំសិនពា៉ កាលនាងនៅក្នុង
គភ៌នៃមាតា ខ្ញុំបានទូលថា នាងនឹងចាកឆ្ងាយ ។
តែថានឹងបាន គូគាប់រួមស្មាន នាំមកពីឆ្ងាយ
មានបុណ្យបារមី រិទ្ធីផ្សាយ សព្វអ្នកទាំងឡាយ
មូលមកវន្ទា ។ ស្ដេចស្ដាប់ហោហើយ ក្សត្រាត្រាណត្រើយ

បន្ទូលត្រាស់ថា ហោអើយបើពិត ដូចពាក្យនោះណា
ទ្រព្យផងផាៗ អញឲ្យរង្វាន់ ។ ទើបព្រះបមហៅ
ព្រះឪស្តត្រាស់ហៅ ក្សត្រីសោភ័ន្ឋ ហៃនាងពុំងារ
ចំប៉ាសុវណ្ណ បុត្រីស្រីប្រាណ ជីវិតបិតា ។
កូនអើយហេតុកម្ម វេរាបងចាំ ពីអតីតា
នាំឲ្យកូនព្រាត់ ប្រាសពីបិតា ឱកូនសង្សា
ដូចចង្វើមប្រម៉ាត់ ។ កូនព្រាត់ទៅហើយ មាសបិតាអើយ
សំបិតាស្ងាត់ ធ្វើម្តេចហេតុកម្ម កូនបានបម្រាត់
គូសង្សាសត្វ បក្សីផងណា ។ ហេតុនោះកូនអើយ
នាងកុំសោកឡើយ ចូរចរយាត្រា តាមកម្មឯងឲ្យ
ផល់ដោយវេរា ស្រីពៅពុំងារ សម្លាញ់ឪពុក ។
បើបង្អង់ខាន កូនស្ងួនកល្យាណ មូលមួយជីទុក
កូនអើយសំព្រាស វិនាសទល់ទុក្ខ ចាំងអង្គឪពុក
ម្តាយនាងក្តីណា ។ សមក្សិណក្សយ័ពិត្យ ប្រលៃជីវិត
ស្ងួនចាំងករោ ជាហេតុពីព្រោះ កូនស្ងួនស្នេហា
នៅកើតវេរា ឬគ្រៀវីងឆ្ងាយ ។ ហេតុនេះឪពុក
ឲ្យស្ងួនបាត់មុខ ជាបុត្រពណារាយ ស្នងជួសជីវិត
អស់អ្នកចាំងឡាយ ទៅតាមកម្មកាយ ពីព្រេងមកណា ។
កើតក្នុងលោកិយ៍ ពុំជៀសបាគតី ទុក្ខសោយសោក្កា

មានកាលសុខសល់ ច្កើនថ្កានសោកា មានកាលមណា
ព្រាត់ប្រាសបាត់បង់ ៗ គួរគិតអនិច្ចា យកព្រះធម៌ជា
ពឹងពាក់សព្វអង្គ សង្វេគមេត្តា ការនាផ្គត់ផ្គង់
ស្មារតីឲ្យត្រង់ តាមពុទ្ធដីកាទថ្ងៃ ៗ ហៃមាសទុពគុណ
ចូរនាងធ្វើបុណ្យ កាលគ្រានេះនៃ បើបុណ្យនាងមាន
រស់បានពុំក្ស័យ កូនបុណ្យធំក្រៃ លើសអស់នាៗ ៗ
នាងនាថសុវណ្ណ បំបា៉រសោកន្ទ ស្ដាប់ព្រះបិតា
ឯងឥតធ្ងះបើយ សាសង៍វាចា ទទួលអាជ្ញា
ទៅតាមព្រះទ័យ ៗ ហើយនាងឧត្តម ថ្វាត់ថ្វាយបង្គំ
លាពីក្សត្រថ្លៃ ព្រះនេត្រជោជន់ អួលអន់ពេកក្រៃ
បំបា៉រមាសម៉ែ រុះចុះពាសពេញ ៗ បពិទព្រះមេ
ជាម្កុដលើសិ វិសាកូនសម្លាញ់ ថ្ងៃនេះនឹងប្រាស
និរាសចាកចេញ សមពុំវិលវិញ បានមកយល់មុខ ៗ
នាក់អើយអ្នកនៅ ខ្ញុំលាអ្នកទៅ គឺទៅទាំងទុក្ខ
ក្ដីចិត្តខ្វាញ់ខ្វល រំជួលពុំសុខ ដូចគេញីញាក់
សាប់ស្ងួតថ្មើមថ្ងៃ ៗ ពុំបានសងគុណ វិសេសមហាធ្ងន់
ធ្ងន់ពិតពេកក្រៃ ទោះទាំងធរណី គឺដែលល្មៃ
ទូរទាំងកពាត្រៃ ពិតពុំស្មើបាន ៗ ខ្ញុំធ្លាប់ឡើងគាល់
ពីព្រះទ្រង់ធម៌ ជាតិជាប្រធាន ឱឥឡូវខ្ញុំ

បែកបំបែកស្ថាន  ហេតុបាបបុណ្យ  បរមជាតិតា  ។
ទ្រឹមនេះទៅ  ពីព្រះបមហៅ  នឹងបានអ្នកណា
តាំងខ្ញុំកូនស្ងួន  ខ្ញុំមខ្លួនពុំឆារ  ដូចសត្វកាលគ្រា
ពីមុនៗមិញ  ។  ក្បែរថ្ងៃឧត្តម  អ្នកធ្លាប់ថ្នមខ្ញុំ
ផ្តេកផ្តិតស្រឡាញ់  និតនៅសព្វថ្ងៃ  ហឫទ័យពិតពេញ
ឥឡូវម្តេចមិញ  បរបាកឃ្លាតឃ្លា  ។  ទ្រូងតឹងស្មើប្រេះ
ខ្សឹកខ្សួលផ្អូកផ្អែះ  អាណិតពេកណា  ពីលាពថ្ងឹងថ្ងៃង
កន្ទ្រង់សោកា  ឧបបាទមាតា  ផ្ចួញផិតនៅហោង  ។
ឯព្រះមាតា  គិតគក់ទក់  ពីលាពយំផង
ថើបថែកគ្រា  ស្រឹបប៉ាវពោង  ថ្នាក់ថ្នមត្រកង
ប្រហោសព្រលឹង  ។  យំហើយយំទៀត  ទក់ចង្អៀត
ក្រាលក្រមតាន់តឹង  កក្តាស្ងួតស្ងប់  សញ្ចប់សញ្ចឹង
ឪបុត្រព្រលឹង  ហើយសោកថ្ងាថ្ងង  ។  ជាទីមាសម្តាយ
ធ្លាប់អ្វីពីនាយ  ឲ្យយើងបម្លើង  ឃ្លាតឃ្លាទៅឆ្ងាយ
ទីទៃកន្តែង  ហើយឲ្យកូនឯង  ជាអាហារកុម្ភី  ។
ខ្លួនម្តាយចាស់ហើយ  ព្រលឹងម្តាយអើយ  ម្តាយចប់ប្រឹនក្តី
ចប់មួយផ្សិតស្ងួន  ខ្ញុំមខ្លួនពីសី  ក្មេងណាស់ណាស្រី
សម្លាញ់ម្តាយអើយ  ។  ម្តេចឡើយមកប្រាស  ព្រាត់ចេញស្រឡះ
ទីទៃប្រងើយ  ម្តាយឈឺផ្តាសសាយ  ឥតឯទាន់ស្បើយ

លេខក្បួន : ..........
លេខបញ្ជី : ..........

ស្រាកស្រាន្តល្ហៃល្ហើយ ណាមាសមាតា ៗ ម្តាយគិតប្រណី
មួយត្បិតជាស្រី តែឯងឯកា ពិតពុំដែលយល់
អម្ពល់ភ័យា ធ្លាប់គង់លើប្រា សានសុខថ្កាថ្ងៃ ៗ
មេទុំភ័លៀង បំពេជ្របព្រៀង បន្ទន់សព្វថ្ងៃ
ពីពេះរំពង អឺងកងទះដៃ សូរសព្ទស្រទៃ
តន្ត្រីអ៊ូអា ៗ តឡូវបុត្រថ្ងៃ បេញបាកដោះដៃ
ទៅតើនរណា ទីងនៅស្អបស្អង គ្រងអស់បន្ទារ ពស្ត្រតាំងនេះណា
ដូចមាសពន្លក ៗ ឱកូនវិសេស នាងកុំប្រហែស
ទៅហើយឆាប់មក ដើរដោយមគ៌ា អាត្មារឈ្ងួនឆក
កុំកូនពន្លក ប្រហែសអាត្មា ៗ នាងផ្គាំសព្វគ្រប់
ប្រាសប្រាណសន្ធប់ តាំងបីអគ្គណា តាំងស្រីព្រះស្នំ
សិងយំសោកា ទួញទលទុក្ខា ទីងនាងស្រីរតន៍ ៗ
យល់ព្រះរាជា សន្ធប់ធ្នោះណា កាន់តាំងរទត់
ហើយយកគង្គារ រងថ្វាពិបត្ត មកហើយក្បង់ក្បិត
លប់ព្រះកន្ត្រា ៗ លុះដឹងស្មារតី ក្សត្រាក្សត្រី
ទួញទៀតច្រើនគ្រា ទើបនាងសោកទុ សុវណ្ណបិប៉ាវ
ទូលព្រះមិតា មាតាថ្វាថ្ងៃ សូមជំព្រះស្នំ
ខិនយាយបាសកុំ គីលៀងសៅដៃ នូវអស់ប្រដាប់
សំពប់នាងនៃ នូវពស្ត្រក្សត្រថ្ងៃ សូមទ្រង់ករុណា ៗ

ទោះខុសទោះធ្ងន់ សូមព្រះប្យុះប្យន៍ ទ្រង់ព្រះមេត្តា
ខ្ញុំទៅតែឯង ឯកោទេណា តាមកម្មវេរា
កូនកាលនេះម្ដង ៗ នាងនាថបវរា សុខសិនបំប៉ារ
បាក់ចិត្តនាងហោង ពិតោសុះសាយ ក្ងិនក្ងាយល្អប់ល្អន៍
អស់តាំងស្រីផង រើសយកគ្រប់គ្នា ៗ ស្រីរតន៍ឧត្ដម
ក្រាបថ្វាយបង្គំ នាងទឹងយាត្រា កាលនោះសោតហោង
រីឯកូនធា ក្រាបក្រោមបាទា សម្ដេចបុត្រី ៗ
ហើយទើបទូលថា បពិត្រអ្នកជា អម្ចាស់សិរី
ខ្ញុំសូមទៅដែរ តាមហែក្សត្រី រួមឯកជីវី
ទឹងម្ចាស់សិរីសោ ៗ ទោះបីកម្មី ចិត្តខ្ញុំខ្ញាំសុំ
នាងជាអាហារ ខ្ញុំសូមរមៀល បូលកន្មាត់រ៉
ស្លាប់រស់ផងគ្នា តទ្បូវនេះម្ដង ៗ បំណាច់មានគុណ
វិសេសមហាធ្ងន់ ពេកក្រៃកន្ទង ទ្រង់ព្រះមេត្តា
ករុណាគ្មាត់ហោង ខ្ញុំទៅទឹងសង គុណគាប់ប្រពៃ ៗ
នាងស្ដាប់កូនធា ទូលសូមអាសារ នោះនាងអរក្រៃ
ត្រាន់ជាកក់ក្ដៅ ដើរទៅដោយព្រៃ ជាគ្នាស្រីថ្លៃ
កំដរសោះស្គាត់ ៗ ហើយទើបក្សត្រី បំប៉ារទេវី
ប្រសើរពេកក្ដាត់ នាងរៀបប្រដាប់ សព្វស្រីរតន
ទុកស្រេបចុះថ្វាត់ តាំងនាងវិទ្យា ៗ ស្រីថ្លៃប្រសើរ

យានយាសចុះដើរ ទូលទៅឯគា ព្រះស្នំទាសី
គីលៀនគេគ្រា គាសួរធិតា ទួញយំអឹងកង ៗ
ឱអម្ចាស់ថ្លៃ បុណ្យបារមីក្រៃ យកយើងទៅផង
ហេតុម្តេចស្តេចទៅ ឯកាដោយផង ព្រោះព្រាយព្រលង
គីរបុត្តា ៗ បំប៉ារស្រីរតន៍ នាងបន្ទូលឃាត់
ព្រះស្នំទាសា មិនឆ្ងាយមកឡើយ ម្ល៉េះហើយឥតគ្នា
រុងនៅគ្រឹះហា លំនៅទំនែ ៗ ហើយនាងធិតា
ស្តេចបរលីលា ចេញទៅឃ្លាតខ្ញី ឯកឯងត្រមោច
កណ្តាបស្រីថ្លៃ ទុក្ខពន់ពេកក្រៃ ដោយផងមាតា ៗ

## នេះបទព្រហ្មគិត

គាឈ្មោះឯកត្រី ព្រះជំនីសោកគ្រាំគ្រា
ជាទុមាសតុំឆារ ហេតុវេកនាំព្រាត់ឆ្ងាយ
ទ្រូងម្តាយដូចគេបោច ក្តៅផ្សាខ្លាចស៊ូនឹងឆ្ងាយ
ឈឺឈៀបឈ្លួលសព្វសាយ អស់កន់កាយម្តាយញ័រញាក់ ៗ
កូនត្រាច់ទៅម្នាក់ឯង ទ្រូងចំបែងស្ងប់ស្ងួតក្រ្ព
ហេតុកម្មអ្វីលក្ខ ឲ្យឃ្លាតបាតពីកជស្ថាន ៗ
ដើរតាមដោយដងព្រៃ ម្ល៉េះព្រះទ័យព្រួយរំខាន
ទៅឲ្យសត្វតិរច្ឆាន ស៊ីកំសានជាអាហារ ៗ
កូនអើយម្តាយសែនកពី ហាក់ដូចម្ជុលគងកាយា

នេះគឺមានវេរា ទើបពុំអាចឃ្លាតឃ្លាចេញ ៗ
សំយើងបានបំពាក់ សង្ក្រាសគ្នាពីមុនមិញ
ទើបជាតិឥឡូវវិញ ឲ្យព្រាត់ប្រាសចាកមាតា ៗ
មួយបើមាសទីមល់ បានទៅដល់ក្រពើណា
ទឹងរូបនោះគាប់ជា ឬមរណាទេដឹងហើយ ៗ
ម្ដាយគិតគូទៅគ្រប់ វេងវៃថប់ៗ ពុំស្បើយ
ព្រលឹងមាសម្ដាយអើយ មាសពុំដែលដឹងទុក្ខា ៗ
មួយសោតមាសប្រសើរ ពុំដែលដើរជាយមាតា
ម្ល៉េះសុំព្រះបាទា ពុះពោតពង់បែករលាយ ៗ
ទៀយណាស់ប្រាសប្រាណផ្ដុំ ទ្រហោយំស្រែករកម្ដាយ
ឱកែវស្រស់ឆោមឆាយ កូននៅឆ្ងាយម្ដេចឮដល់ ៗ
នាងសោកៗប្រាសប្រាណ ព្រួយរំខានលើមន្ទល់
ព្រោះតែកូនទីមយល់ នាងនិរាសទៅហើយហោង ៗ

## នេះបទកាកគតិ

នេះទឹងស្រដី នាគាលនាងស្រី ចំប៉ាសុវណ្ណ
ត្រាច់តែឯកា ហាក់ដូចព្រះចន្ទ ដំណើរល្ហាសល្ហូន
ចាកទិសបូព៌ា ៗ រមិលមើលក្រោយ ទិមុខគួរឲ្យ
ស្រណោះណាសក្ដ ពដកង់ប្រាសាទ សោតសិងឃ្លាតឃ្លា
ថ្ងៃនេះហើយណា ខានបានយល់ហោង ៗ នាងគ្របកគ្រា

ពុំឲ្យអ្នកណា ស្គាល់នាងប្រុះប្រូន នាងដើរបានដល់
ជល្សា ជាម្ដង បំប៉ារទួនល្អង ដើរវៀនមាគ៌ា ៗ
នាងឥតសោកសៅ ព្រះឥស្ដហាហៅ ក្រពើហៃបា
បើចង់ស៊ីអញ ចូលមកឆាប់ក កុំបង្អង់ការ
ឥឡូវនេះថ្ងាត់ ៗ ឯអង្គកុក្កី លុះត្រូសំដី
នាងស្រីវរតន៍ មិម្មាហើបហែប ផ្ទះផែលឆាប់ក្ដាត់
ប៉ិនទឹងបំបាត់ ជីវិតនាងណា ៗ ដោយដៃកស្ទុះមក
រំពងរលក ពារពុះគង្គារ បោកបែកផ្កាត្រែង
រំដួលជល្សា ដូចព្យុះព្យាមា សន្ទឹកព្រួរ ៗ
យល់នាងបំប៉ារ ត្រេកក្នុងចិន្ដា ទិកមានអំណរ
ដោយដូចបំណង ដែលប៉ិនទិកអរ បោកទឹកខ្លាខ្លូរ
សាហាវហានក្លា ៗ ហើយស្រែកស្រដី ថាហៃនាងស្រី
សុវណ្ណបំប៉ារ បើនាងនឹងឲ្យ អង្គអញកាំក្ដា
ចូរចុះមកក៏ កុំឲ្យយូរឡើយ ៗ អញទន្ទឹងពេក
យល់យូរចម្លែក ជិតមួយឆ្នាំហើយ កម្រនឹងឃើញ
ប្រាប់មកនាងអើយ អញនឹងស៊ីហើយ កុំកូតមុសា ៗ
ស្រីបំប៉ារថោង ស្រដីសាសង ទៅក្រពើថា
អញបានជាយូរ ត្បិតព្រះមាតា ពុំឲ្យយាត្រា
មកដូចបំណង ៗ ឥឡូវនេះណា ខ្ញុំយាងឯកា

ដើរដោយប្រលង ថាអេះអញធ្លល់ ផ្ទៃកសល់កន្ទង
អញមានគុណផង ចិញ្ចឹមរក្សា ៗ គិតថានឹងតាប់
ម្ដេចឡើយត្រឡប់ ទៅជាទោសា ក្រពើព្ញហើយ
ឆ្លុះឆ្លើយវិញថា ហៃនាងបំប៉ារ សុវណ្ណទេវី ៗ
កាលទ្រង់បង្ហាំង នៅនាគ្គងរាំង ក្នុងល្អាងមាសថ្មី
យូរណាស់លំបាក រង់ទុក្ខឥតបី ហាក់ពុំប្រណី
អាសូរមេត្តា ៗ ហេតុនោះអញខឹង ឥឡូវអញនឹង
បរិភោគហើយណា គុណាក្រអឺមាន មកហ៊ានបរវា
ទោះនៃអាត្មា ធ្វើបេះស្រដី ៗ គន់មើលទៅស្បែក
គួរឲ្យយល់ផ្ទៃក ហាក់លាបខៀវខ្ចី មានរសទជា
ពិសាតិចអ្វី ះបាតបុះមកខ្វី អញនឹងភោគា ៗ
ក្សត្រីត្រាណត្រើយ សាសង់ឆ្លុះឆ្លើយ ក្រពើហៃហា
បើអ្នកនឹងស៊ី អង្គអញក្តីណា អញឥតបើថា
អ៊ីឡើយនេះម្ដង ៗ តែឈប់កុំអាល ឲ្យឆ្ងាយស្រយាល
អ្នកនគរផង នៅនេះអញខ្វាស រសាត់ស្រ្តកន្ទង
ផល់ជ្រោះមួយហោង តាមចិត្តនៃបា ៗ ក្រពើស្ដាប់ហើយ
ហៃលសៀបឆ្កើយ ប្របឆ្នួដល្ងសា តាមរាជទេវី
នាងស្រីបំប៉ារ នៀយណាស់ក្រោធា ខេខឹងពេកក្រៃ ៗ
នៃនាងបំប៉ារ ផ្លិតផ្លង់ដល់ណា មិនបុះមកនៃ

អញនោតដើរតាម  រកមេប្រឹនក្រៃ  ល្ងឹនល្ងើយរវ័យ
ពុំខ្លាចឡើយណា ៗ  ថាដើរទៅមុខ  ឆ្ងាយក្រៃពីស្រុក
មកគាល់ព្រឹក្សា  ដល់ឈូងខណ្ឌព្រៃ  តាមដោយនាងថា
ឆ្ងាយក្រៃហើយណា  នាងកុហក់លេង ៗ  កាលៈនាះវឡា
ក្តៅក្នុងចិន្តា  ពេកពន់ពុំក្រែង  ថាកុំស្រែកហៅ
ព្រះនាងក្តែង ៗ  ពេលនេះអញឯង  ពុំឲ្យទៅឡើយ ៗ
នាងមានគុណគាប់  អាប្រែត្រឡប់  ជាទោសប្រើយ
បំភ្លេចគុណគេ  ឆ្មុះឆ្មើកន្តើយ  បើគាប់ឲ្យហើយ
ពីកាលនៅក្មេង ៗ  នោះប្រសើរលើន  បំណាច់ល្មើសគុណ
វិសេសស្ងប់ស្ងែង  បុកទ្រើសទ្រនុង  បុណ្យប្រាបឥតក្រែង
ឥតមានរអែង  គុណគេប៉ុនសក់ ៗ  អាចិត្តមោបោ
គង់រង់ទុក្ខា  ទូវនានរក  ពុំដែលហៅស្បើយ
ល្ហៃល្ហើយរងទុក្ខ  កុំស្មានថាសុខ  ដូចចិត្តប្រាថ្នា ៗ
មួយកុំសង្វាត  ចាំហែលខ្ញីឃ្លាត  តាមនាងធិតា
ពុំគិតព្រួញប្រាណ  ចង់បានកោក្កា  ដំណើរអ្វើ
ទង់បានស៊ីងាយ ៗ  ក្រពើស្តែង ស្តាប់  ឮពាក្យពុំគាប់
វែងក្តៅក្រហាយ  ថាវើយតិរច្ឆាន  ប្រាណគង់អន្តរាយ
ធ្វើបេះនាយកាយ  ពុំខ្លាចខ្លួនណា ៗ  ហើយហោះលោតភយ
ខ្ទួតទឹកព្រោងព្រាយ  ទ្រលោមសោះសា  ពុំត្រូវក្សត្រ

ទេវីបំពារ ក្រោធក្រែមហិមា ស្ទើដាច់ខ្យល់ក្លាម ៗ
ស្រីរតន៍ប្រសើរ ទំយានយាសដើរ លង់លុះដល់ឋាន
មួយនោះទើសទាត់ ខានចុនដល់ស្ថាន ហើយស្រីកល្យាណ
បួលថ្វាយវន្ទា ៗ បពិទទេពព្រាហ្ម លោកជាទិព្វចក្ខុ
សូមមានមេត្តា ទោះទាំងព្រះឥន្ទ្រ នរិនទេវា
សូមជួយករុណា អាត្មាខ្ញុំផង ៗ ក្នុងពេលនេះណា
ឲ្យរួចជន្ទា ឥឡូវនេះម្ដង ព្រោះសត្វក្រពើ
មោហាជ្រើសឃ្នង ឲ្យបានរំលង ភ័យកិតសោកា ៗ
តេជះសំណាង អញខ្ញុំបានសាង ពីអតីតា
សូមឲ្យអស់ផល កុសលសីលា ជូនជួយករុណា
កុំឲ្យអន្តរាយ ៗ ហេតុបុណ្យបារមី សម្ដេចក្សត្រី
អំពីព្រេងនាយ ក្ដៅដល់អាស្នា ឥន្ទ្រាពណារាយ
គង់ពុំសប្បាយ ជាហេតុអស្ចារ្យ ៗ ស្ដេចបើកទិព្វចក្ខុ
យល់នាងវរលក្ខ័ ស្រីថ្ងៃសោកា អួលអន់សោយសោក
អាមោកក្ដាត់ណា តែឯងឯកា ដោយជនីអាត្មា ៗ
ព្រះឥន្ទ្រហោះឈ្យាន ចុះចាកសួគ៌ស្ថាន ដល់ផែនកស្យណា
ឯអង្គព្រះឥន្ទ្រ នរិនថ្ងៃថ្វា និម្មិតជាផ្កា
ឈូកមួយធំក្រៃ ៗ គឺមោះសិង្ហពិស ប្រាកដជាក្រេស
ផុះប្រិបផល្ងៃស វេលានោះណា ចំប៉ារស្រីថ្ង

នាងចុះឃ្លាតខ្ចី ទៅកាន់ផល្សា ៗ នាងនាថសោភណ្ឌ
ចំប៉ាសុវណ្ណ ផ្លែផ្កាកូនខ្ចី ថាចូរនាងទៅ
ទឹងព្រៃព្រឹក្សា នាងអើយអញលា ទៅឋានកុម្ភី ៗ
កាលនោះវិទ្យា ស្ដាប់នាងធីតា ផ្លែផ្កាស្រសី
ទូលថាខ្ញុំសូម ទៅតាមក្សត្រី រួមឯកជ័រី
ក្នុងមាត់កុម្ភា ៗ នាងនាថស្រីថ្លៃ ស្ដាប់ព្រួសម័យ
នាងកន្ទុះភា ហើយនាងទេវី មេត្រីត្រាស់ថា
តាមចិត្តវិទ្យា ដែលប៉ងបង់ទៅ ៗ ហើយនាងក្សត្រី
លីលាចុះខ្ចី ត្រាច់ចរសំដៅ ទាំងនាងវិទ្យា
យាត្រាចុះទៅ ត្រង់ក្រពើនៅ នាមឆ្គង្គារ ៗ
នាងនាថស្រីពៅ ព្រះឧស្សាហាហៅ ហៃក្រពើថា
បើអ្នកចង់ស៊ី អង្គអញក្ដីណា ចូរឆាប់ស្រវ៉ា
កុំប្រាចង្អង់ ហើយស្រីវរវង្ស ស្ដេចឡើងទៅគង់
លើផ្កាឈូករហាន ត្របកប្រទុម ក្រពុំឥតហ្មង
ទ្រេតទ្រោមល្ហាយល្ហង គោរពធិតា ៗ កាលនោះកុម្ភី
ព្រួហើយឃ្លាតខ្ចី ផ្លុកផ្លោះសោះសា កន្ទុយរាសរាត់
ខ្វាយខ្វាត់គង្គារ គៀគរហើយហា ចេញផ្លូវដែកគោល
ចង្កូមសរសោច មើលទៅគួរខ្លាច ប្រែប្រាសស្រុះចូល
លាលោតត្របាក់ ផាប់មាត់កញ្ជ្រោល ដូចគេបស់ចោល

ទៅលើកស្បងា ៗ ត្រុះស្បែករយាក ដាច់សាច់ធ្មេញធ្លាក់
ឈូកដូចដង្ហា ស្រាវសរសៃស្អួត ឃ្លាតចេញពីគ្នា
ក្រតើមោហា លោហិតហូរខ្ចាយ ៗ ស្រែកពេកខ្លាំង
នរទៀលលើច្រាំង ឈឺសប់ពងកាយ ប្រឡោះបោកបស់
ស្ទុះលោតប្រតាយ សៀមស្ទាត់ទៀយណាយ ជីវិតមរណា ៗ
រំពងទេវី បំប៉ារទ្ទី នាងធ្មុបនេត្រា
ពុំដឹងក្រពើ សូន្យផន់ដីហ៊ី ខំតែការនា
ទិកដល់ភូមរណ៍ កាលនោះទេព្ដា ទាំងនរកម្ពា
មូលមកឲ្យពារ អឹងអាប់ពិហារ ព្រះទ័យត្រេកអរ
នឹងនាងបវរ រូបរស់ជន្មា ៗ ហើយទេបព្រះឥន្ទ
ទ្រើសទ្រង់នរិន្ទ បន្តូលត្រាស់ថា ហៃមត្តកន្ទឹ
ចូលមកតាប៉ក់ ប្រាណាប្រែកាឡា ដាក្អកថ្លាតផង ៗ
ព្រះមត្តកុន្ទល ត្រូញក្រោបរទ្ទី នរិន្ទប្រុះប្រឹង
ធ្វើតាមអាជ្ញា កាឡាដូចប៉ង ថ្លាតក្អកស្រែកគង
ទោមបិតសោះសា ៗ ទង់ទាញហូរហែក ដង្ហោនបិតក្អក
ជណ្ដើមកោក្ដា ហេតុបាបក្រពើ គិរត្តីមោហោ
មោហៈពាលា បំភ្លេចគុណគេ ៗ ទិព្វទេព្វទេព
ទូលទាងបំប៉ារ សុវណ្ណមាសមេ អញ្ជើញធិតា
យាត្រាប្រាណប្រែ ក្រឡាប់វិលដៃ ប្រាសាទវិញនៃ

ឥឡូវក្រពើ ក្បិនក្បួយហើយតើ នូវឆ្កែដល់សៃ
ក្អែកត្មាតខ្មៅខ្វល់ ហែកហួរក្រញី អញ្ជើញក្បែរ
លីលាឡើងលើ ។ រីនាងបំប៉ារ បើកព្រះនេត្រា
ទតយល់ក្រពើ ស្លាប់នៅប្រាំង ក្អែកត្មាតកកេរ
បំប៉ារប្រសើរ ក្រោកដើរទៅខ្ចី ។ ពីឈូកសុវណ្ណ
នូវនាងវីឡា ស្រាកស្រាន្តទុក្ខភ័យ កាលនោះកក្រើក
ញាប់ញ័រប្រឹថពី ដោយតេជះបារមី ស្រីថ្លៃបំប៉ារ ។
នាងចូលទៅថ្កាន ទិព្វទេពពជស្ថាន ថ្វាយវន្ទា
សរសើរព្រះគុណ ត្បិតបុណ្យទេវតា ជួយជូនកាលគ្រា
នោះនាងអរក្រៃ ។ ហើយនាងជិតា ប្រទក្សិណលា
ទេពព្រក្សនោះនៃ ត្រាច់ចរយាត្រា ឯកាស្រីថ្លៃ
ឥតអ្នកដទៃ កំដរជាគ្នា ។

## នេះបទព្រហ្មគិត

ការល្មោះអគ្គក្សត្រី ព្រះជីនវង្សខ្ចាបផ្កា
នាងវង់ទុក្ខសោកា វង់ចន្ទន៍ពជបុត្រី ។
ថាទស្សនសង្ឃា ល្អត្រកាលអស់ស្ត្រី
នាងរស់រួចជីវ៍ បុមាសម្ដាយក្បួយជន្មា ។
ទុកឥតអ្នកវិលថ្កាន ម្ដាយទើបបានដឹងដោយសា
ដំណើរពៅពីតា ម្ដាយខ្ចាបផ្កាឥតល្ហៃល្ហើយ

ម្ដាយទន្ទឹងទុក្ខធំ បុត្រចតន់រូបមកហើយ
ខុះឱសួនម្ដាយអើយ ម្ដាយថប់ពេកក្រែងកូនគ្រាច់
ដើរដោយផងព្រឹក្សា ពើបអម្រិគាយង់យ្ហង់កាច
រាប្រហាផ្ដិលផ្ដាច់ ជីវិតកូនធ្វើអាហារ ៗ
ថប់មួយកូនពុំដឹង មាតាក្ដិកង់ព្រៃអាធ្វា
សំកូនសួនកំព្រា ទឹងរ៉ះធ្វើងដោយទុរគុំ ៗ
នាងខ្លួញរកបុត្រ ហើយទេវតាឧត្តម
ឲ្យហៅស្រីព្រះសុំ មកដល់ហើយទ្រង់ត្រាស់ថា ៗ
នាងអើយចូរនាងទៅ តាមស្រីពៅមាសបំប៉ារ
ឲ្យដឹងអស់កិច្ចការ សោះអញថប់ណានាងអើយ ៗ
ស្រីសុំស្ដាប់ហើយលា ថ្វាយវន្ទាពុំយូរឡើយ
រួសពនចេញជាត្រើយ ត្រាប់តាមរកវៀងមាតា ៗ
ដើរដោយប្រែកដ្រលង បំប៉ារផងប្រើនត្រៀបត្រា
ដែលជ្រុសចាកទិស្សា នៃនាងនាថកាលស្ដេចទៅ ៗ
ឃើញហើយទំរើសទុក រូបគ្រុកដើរសំដៅ
កន្ទួងក្រពើកូវ ពិតពុំយល់នាងឡើយណា ៗ
រុករកសប់ជ្រោះជ្រៅ ដ្រលងនូវព្រៃព្រឹក្សា
ពុំយល់នាងបំប៉ារ ត្រឡប់សាវិលវិញខ្ចី ៗ
ចូលទៅថ្វាយវន្ទា នាងជាយាម្ចាស់សិរីសើ

ថ្វាថ្ងៃអស់សេចក្ដី    ពីដំណើរដោយមាគ៌ា    ៗ
សូមទានយើងខ្ញុំទៅ    ដល់ព្រៃព្រៅឆ្មេះដល្ហសា
បាចសាចដោយមាគ៌ា    ពិតពុំយល់រាជបុត្រី    ៗ
យល់តែផ្កាបំបារ    ជ្រុះទូវនាតាមធានី
ខ្ញុំរកសត្វទៃទទី    ពុំបានយល់ដូចប្រាថ្នា    ៗ
ហើយមានរើសផ្លែឈើ    ណាដែលជ្រុះដោយពស្យធា
សាក្សីមានតាំងផ្កា    សូមជ្រាបក្នុងព្រះហឫទ័យ    ៗ
នាងស្ដាប់សត្វស្រីស្នំ    សែនក្រៀមក្រំអួលអាល័យ
ថាឪមាសថ្មើមថ្ងៃ    ម្ដាយឲ្យរកសត្វទូលទី    ៗ
មាសម្ដាយនាងមកហើយ    ប្ដូនៅឡើយសួនពិសី
ពុំមានដំណឹងអ្វី    ពាមាសមកដល់ម្ដាយណា    ៗ
ថាឪអាសូសល់    ម្ដេចមកយល់តែបំបារ
រុះរៀងដោយមាគ៌ា    ម្ដាយវែងវង់ទុក្ខក្ដាត់ក្ដៅ    ៗ
ស្រណោះស្រស់ដីរ៉ា    ក្លិនបំបារជាប់និតនៅ
ប្រហើប្រហែលពៅ    មាសសម្លាញ់ថ្មើមមាតា    ៗ
កាលនោះឲ្យតាក់តែង    ដោយដំណែងនាងនា ៗ
ធ្វើបុណ្យឲ្យទានជា    ផលបំរើនរាជបុត្រី    ៗ
សូមឲ្យអស់បុណ្យនោះ    ជូនបំពោះទៅទេវី
បំបារសុវណ្ណី    ឲ្យរំលងទុក្ខទោសា    ៗ

ស្តេចទ្រង់មន្ត្រីផង មកក្រាប់ត្រង់ស្តាប់ទេស្នា
ឲ្យរំដោះគ្រោះពាធា បានស្រាកស្រាន្តស្រយាលស្បើយ ។
ហើយនាងតែងក្រវើន ទ្រង់ចំរើនពិលុះទៀយ
យកព្រះធម៌ជាត្រើយ ជាទីពឹងនាសប់ថ្ងៃ ។

## នេះបទភុជង្គលីលា

ទីនថ្ងៃនសំដែងចរចា សុវណ្ណចំប៉ា ដើរដោយដងព្រៃ
ត្រមោចកន្ទោបពេកក្រៃ ឥតអ្នកដទៃ ទីងនាងវិទ្យា ។
ដើរដោយជ្រោះជ្រៅអាក្ងារ ជួនយប់សន្ធ្យា ចូលចតអាស្រ័យ
ពិងពាក់សំណាក់ដើមជ្រៃ វស្សាទនោះនៃ ទេព្តារក្សា ។
នាងផ្ទុំសំងំខ្ទោបផ្កា គិតដល់បិតា មាតាដៀសជ័យ
មាតសត្វប្រព៉ក់តាំងព្រៃ រំតៃតអាល័យ អាលឹកពេកណា ។
ព្ទមាត់ខ្វិនខ្ទោបផ្ទាម្ពា ឥឡូវសោកណា ទីទុយមៀមមុំ
ខ្វិនស្រោកផ្លោះផ្លាកយាសយំ តាំងគួចចំ សំម្រែកខ្វាំងក្រៃ ។
នាងស្តាប់សារសព្ទនោះនៃ ត្រីព្រួបហបុទ័យ ខ្វាបសត្វយន់យួន
រំងំរេតទឹកអាណាំតអត្ថ ទីងបុរជន មាតាបិតា ។
នាងទួញទំនួញថបថា ចុះទឹកអន្ធ្យា ទុក្ខពេកកន្ទង
លុះលក់តាំងទុក្ខទៅហោង សប់ស្លាត់ឥតហ្វង យប់យូរហើយហោ ។
ស្រាង១បំព្រាងបុត្តា រំង់រះសុរិយា ប្រះព្រាលរស្មី
នាងនាបត្រកាលឃាតខ្វី សំរោះទៅទី ទេព្តានោះនៃ ។

នាងថ្វាយកកាយល្មមល្អៃ　សប់ជានទំនៃ　តាំងទេព្តថា

បពិទទិព្វទេពទេវ　សូមអ្នកករុណា　ឥឡូវនេះម្តង ។

ខ្ញុំទៅដោយផ្លូវប្រែលង　សូមទេព្តាផង　ជួយជូនរក្សា

បើដល់មន្ទួលស្រុកណា　សូមឲ្យក្សត្រា　ឥស្សូនគ ។

មេត្តាករុណាត្រេកអរ　ទទួលសាទរ　យកជាបុត្រក្វា

អស់អញស្រឡាញ់ពេកណា　ស្មើបុត្រអាត្មា　ពុំមានសៅហ្មង ។

ធិតាបរបាសាសង　ស្រេចហើយបរផ្គង　ដើរតាមមាគ៌ា

ទីងថ្កានទីស្ថានអាត្មា　ខ្មាសអស់សេនា　មុខមន្ត្រីផង ។

នាងគិតក្នុងចិត្តស្រេចហោង　ក្សត្រីប្រះប្រង　នាងពុំវិលវិង

ត្រេបកាត់ក្នុងព្រៃស្ងាត់ឈឹង　លូតលាស់ស្រោងស្រឹង　មានម្លប់សាខា ។

ស្រីថ្ងៃដើរព្រៃព្រឹក្សា　ស្រគៀបធារា　ពោពង់ពកព្រៃ

ព្រះនេត្រហូរហោតុអាល័យ　នឿយកាយស្រីថ្ងៃ　ឈរឈប់សម្រាន ។

មែៗ ហឫទ័យពុំក្សាន្ត　ទិកទៅឯស្ថាន　សុំស្និទស្នេហា

កន្ទង់ហើវង់វេភ　ត្រង់ត្រាប់បុប្ផា　កេសររុះរោយ ។

អម្រឹតពទ្ទឹកដើរដោយ　ភ្ញីងភ្ញូរឲ្យ　ស្រណោះពេកណា

នាំកូនប្រពន្ធត្រៀបត្រា　ពូនពាក់ស្ពាគ្នា　ញ៉ែងញ៉ងកៃក្រោយ ។

តែអញម្ដេចមិញចាកឆ្ងាយ　ទំនៃព្រាត់ព្រាយ　មាតាបិតា

ទីកសព្រាត់ប្រាសឃ្លាតឃ្លា　ថាត់បង់ឱជា　ទុក្ខពន់ប្រមាណ ។

នាងយំក្រៀមក្រំពុំក្សាន្ត　នទៀលប្រាសប្រាណ　លើផែនពសុធា

សន្ទូប់ចំប្រប់អង្គា　ឯកឯងនូវនា　ព្រឹក្សព្រៃទុរគម ៗ

## នេះបទកាកគតិ

កាលនោះវេឡា　ភ័យគិតអស្ចារ្យ　យល់នាងទេវី
កាលដួលសន្ទូប　ស្លុតស្លប់ស្មារតី　នាងវែងគិតភ័យ
ពីណាពាពេកណា ៗ　អម្ចាស់ខ្ញុំអើយ　អ្នកសុគត់ហើយ
បាត់បង់ជន្មា　ប្ដូមួយសន្ទូប　ខ្ញុំចប់គ្គាត់ណា
ខ្ញុំឈឺទ្រោចផ្សា　អស់អង្គឥន្ទ្រិ ៗ　ប្ដូម្ចាស់ទុក្ខម
អ្នកបាកបោលខ្ញុំ　នៅនាព្រឹក្សព្រៃ　ទុគិមស្រងាត់
សិងសត្វអម្រឹគី　យង់យ្នងតិរ្យ　សាហាវមោហា ៗ
អម្ចាស់ទុក្ខម　កំណត់ទឹងខ្ញុំ　រៀងមកសប់គ្រា
តុំដែលឲ្យអាក់　ចាំងចាក់ចិន្តា　វៃងទ្រង់ករុណា
អាសូពេកហោង ៗ　មួយបើនៅស្រុក　មានព្រះជីទក
ជីទីបព្រាស់ប្បង　ទ្រង់តែងករុណា　តំងាស្នេស្នង
មេមត់ពេទ្យផង　ពោមចាំរក្សា ៗ　នេះម្តងតែខ្ញុំ
កណ្ដាលទុគិម　តតមានអ្នកណា　មួយមកពីស្រុក
កិដរជាគ្នា　ពីកាក់រក្សា　ប៉ទ្រទៀយហោង ៗ
ក្សិណនោះវេឡា　សែនសោយសោកា　ហើយបរបុះផ្គង
រត់រកគង្គារ　ម្ទីមាកន្ទូង　គ្រាប់កាត់ដោយដង
ដល់ស្ទឹងមួយមាន ៗ　ទឹកសិងវេងថ្លា　ទើបនាងវេឡា

បរបុះទៅបាន　　បៀមទឹកនោះស្រេច　　បរត្រាច់វិលថ្កាន
ដល់រាជកល្យាណ　　ហើយប្រឹងព្រួសស្តោះ ៗ　　ត្រង់ទក់ស្រី
ទើបទៅទៀតខ្ចី　　ពីរបីសាស្ទោះ　　ព្រួសសព្វកាយា
បំបារស្រីស្រស់　　គ្មានស្មារតីសោះ　　វីឡាក័យខ្លាំង ៗ
ចំផាសនឹមទួន　　ទូងទាញអង្រន់　　រួតរិតកាយាំង
យូរណាស់មហិមា　　វីឡាកាន់កាំង　　ទ្រង់តឹងវេណា នតាំង
ហើយស្រែកយំថា ៗ　　ឱម្ចាស់ខ្ញុំអើយ　　ស្តុកស្តឹងល្ងឹងល្ងើយ
ពុំដឹងយ៉ាងណា　　សូមបើកព្រះនេត្រ　　ទតមើលខ្ញុំ
ម្តេចផ្តេះណា　　ហាក់ពុំប្រណី ៗ　　សូមម្ចាស់បរបា
សំណោះសំណាល　　មកវីឡាថ្ងៃ　　កុំឲ្យខ្ញុំព្រួយ
តែឯងក្នុងព្រៃ　　ប្តីម្ចាស់ខ្វល់អ្វី　　អំពីនាងខ្ញុំ ៗ
រៀងមកសព្វដង　　ទ្រង់ធ្លាប់សាសង　　រកទូលបង្គំ
ឱម្ចាស់ខ្ញុំអើយ　　កុំទ្រង់សំងំ　　តើនឡើងនាងខ្ញុំ
ទ្រង់ក្រំស្មើក្ស័យ ៗ　　ហើយនាងវីឡា　　អាទិស្តានថា
ឱទេវ្តាព្រៃ　　ទោះតាំងទេព　　នៅនាសួគ៌ថ្ងៃ
នឹងព្រះកោសី　　សូមលោកមេត្តា ៗ　　ចុះមកសឡូវ
ជួយជីវិតពៅ　　ពន្ទុកបំប៉ារ　　ឲ្យបានរួចរស់
ក្នុងពេលនេះណា　　ឱម្ចាស់សិរសា　　លោកមានបារមី ៗ
ឯអស់អម្រឹត　　ត្រៀបត្រាពន្ទុក　　លុះត្បុសំដី

នាងវិទ្យាទួញ　ទំនួញអស់ក្ដី　សិងតែប្រាណី
ហើយសោកគ្រៀបគ្រា ។ អឹងអាប់រំពឹង　សិងសព្វសត្វផង
ទួញទល់ទុក្ខា　អាណិតកល្យាណ　សុវណ្ណបំប៉ារ
ទឹងនាងវិទ្យា　ពេកពន់ប្រមាណ ។ ក្រកើកក្ដាត់ក្ដៅ
ទូទ័រៈបំនៅ　កោសីប្រធាន　ពុំអាចទឹងនៅ
លើអាសនៈបាន　ស្ដេចលីលាថ្កាន　ចុះដល់ព្រឹក្សា ។
ទើបប្រែទ្រូ　ជានាគទាំងគូ　សឹងមានរិទ្ធា
ចូរចូលប្រយុត　រិតរួតពាន់ពារ　ក្សិណាមួយនោះណា
ចាលចាញ់ក្សិណាក្ស័យ ។ មួយលូនទៅរក　កកេថ្ចាំមក
ព្រួសប្រញាប់ក្រៃ　សិងមានជីវិត　រស់ដូចប្រក្រតី
លូនលឿនវិលវៃ　កាត់ព្រៃទៅហោង ។ រីឯវិទ្យា
កាលឃើញនាគ្គា　ភិតភ័យកន្ទង　រត់រកលាក់ខ្លួន
ពឹងពួនជាម្ដួង　មើលនាគទាំងសង　ដឹងដោយប្រាថ្នា ។
នាគទៅស្រេចហើយ　បាត់ពុំលង់ឡើយ　រីនាងវិទ្យា
ទៅកកេថ្ចាំ　នោះមកម្នីម្នា　ព្រួសនាងបំប៉ារ
សុវណ្ណទេវី ។ លុះបានតបទៅ　បំប៉ារស្រីពៅ
បានដឹងស្មារតី　ក្រោកឡើងម្នីម្នា　មានសុវណ្ណី
វិទ្យាហេតុអ្វី　ពុំដាស់អញផង ។ ឯនាងវិទ្យា
ស្ដាប់ស្រីបំប៉ារ　ទើបទូលវិញស្នង　បពិទស្រីថ្លៃ

ម្ចាស់ក្ស័យហើយហោង　គេជះខ្ញុំផ្សង　នូវអស់ទេវ្តា ៗ
សិងមាននាគរាជ　រិទ្ធីអំណាច　ចាំងពីរអគ្គា
មកដល់ចឹងខាំ　ពានពាំពាធា　មួយមិញមរណា
ក្សិណក្ស័យជីវី ៗ　រីមួយទៅខាំ　កកេយកថ្នាំ
ព្រួសអស់ឥន្ទ្រិយ　បន្តិចទើបបាន　ប្រែប្រាណវិលខ្លី
សេរួបជីវី　លួនទៅឯងណា ៗ　ខ្ញុំឃើញហើយខ្លាច
ពេកពានពុំអាច　ទីងទប់អាត្មា　ខំរត់ទៅពួន
លាក់ខ្លួនសស់សា　លុះនាគយាត្រា　ទៅហើយទើបខ្ញុំ ៗ
ទៅយកថ្នាំនោះ　មកហើយខ្ញុំស្ដោះ　ស្រីរតន៍ឧត្តម
ភ្ញាក់ភ្ញាក់ស្មារតី　ក្សត្រីសួរសម　តើនរាកបន្ទុំ
ឥឡូវនេះណា ៗ　នាងស្ដាប់សំដី　ពាក្យរីឡាខ្ញី
ទូលទើបនាងថា　នាងអើយអរគុណ　លើសលន់មហិមា
ផុតពីមរណា　ឥតអ្នកផងយល់ ៗ　ហើយនាងម៉្លា
រួសរាន់យាត្រា　ចេញចាកមន្ទល់　ដើរក្នុងបុត្តា
អាត្មាថ្នាក់ថ្នល់　ឯកឯងទុំពល់　ទីងនាងរីឡា ៗ
មើលជ្រោយមើលជ្រោះ　ព្រៃស្បាតបន្ទោរ　ខ្ពង់ខ្ពស់ៈសាះសា
នាងតែងស្រណោះ　អាឡោះក្ដាត់ណា　នឹកដល់មាតា
ទ្រង់ព្រះកន្សែង ៗ　ខ្សឹកខ្សួលពីលាព　ទន់អគ្គស្រពាប់
ស្រពោនថ្ងាថ្ងៃ　ផុះផុអនិច្ចា　កំព្រាម្នាក់ឯង

កន្ដោបកន្ដែង ត្រមោចឯកា ៗ ចំប៉ាស្រីថ្ងៃ
លេបកលបួលព្រៃ ទឹងនាងវិទ្យា រំលងពីរខែ
ត្រាច់កន្ទុំបុត្តា ពរពងបាទា កក្ដាសៅហ្មង ៗ
ណាខ្លាចសត្វព្រៃ សិង្ហគោដំរី ខ្លាខិនដំបង
ស្រែកឮខ្លាំងក្រៃ ដេញគ្នាតឹកកង នាងភ័យកន្ទូង
ទ្រង់សោយសោកា ៗ និកអាសូកាយ ពុំគួរបែកឆ្ងាយ
ដើរដោយព្រឹក្សា ពុំដែលឃើញមនុស្ស មានតែអម្រឹគា
កំដរដាគ្នា ហាក់ដូចសត្វព្រៃ ៗ

(ខ្សែ ១ សន្ទួបតែប៉ុណ្ណោះ)

ខ្សែ ២ ដើម យក្សដេញចាប់នាងចំប៉ាថោង

កណ្ដាល ទេវតាឃើញ ជ័យដេតកុមារ ទ្រង់ប្រាប ថាត្រូវជាគូទឹងនាង ចំប៉ាថោង ទើបទ្រង់ក្លែងធ្វើជាប្រើសមាស ដើម្បីឲ្យ ជ័យដេតកុមារដេញតាម ៗ

ចុង មានទេវតាចង់បាននាងចំប៉ាថោង ទើបសូមឲ្យព្រះនរាយដណ្ដឹងឲ្យ ៗ

# សៀវភៅដែលផ្សាយចេញពីគេហសាន គីម-គី

| | | |
|---|---|---|
| បកិណ្ណកបរិត្ត . . . . . . . . . . . | ១ សៀវភៅថ្លៃ | ១២'០០ |
| ទេវតាភាសិតនិងពុទ្ធភាសិត . . . . . . . | ,, | ៨'០០ |
| សម្ភារសិក្ខាបទ គោលសិក្សាជំនួយធម្មវិន័យ . | ,, | ១២'០០ |
| វេយ្យាករណបាប់ទី ១ . . . . . . . . . | ,, | ១៨'០០ |
| ,, ,, ទី ២ . . . . . . . . . . . . . | ,, | ១៧'០០ |
| វេយ្យាករណ៍ខ្មែរ . . . . . . . . . . . . | ,, | ១៣'០០ |
| លេខទៀវ . . . . . . . . . . . . . . | ,, | ១៥'០០ |
| បត្តិទានាទិគាថា គឺឥមិនាប្រែ . . . . . . | ,, | ៦'០០ |
| ធម្មបញ្ហា . . . . . . . . . . . . . . | ,, | ៦'០០ |
| បញ្ញានិទ្ទេស . . . . . . . . . . . . | ,, | ២៥'០០ |
| សមាធិនិទ្ទេសសង្ខេប . . . . . . . . . | ,, | ៣០'០០ |
| ប្រស្នាគិហិបដិបត្តិ. . . . . . . . . . . | ,, | ១៨'០០ |
| វិធីប្រែបាលី . . . . . . . . . . . . | ,, | ២៥'០០ |
| ប្រស្នាអភិធម្ម . . . . . . . . . . . | ,, | ២៥'០០ |
| ប្រស្នាត្រៃគុណ . . . . . . . . . . . | ,, | ២៥'០០ |
| សាមណេរវិន័យបញ្ហា . . . . . . . . . | ,, | ១៨'០០ |

សៀវភៅកំពុងបោះពុម្ព ឬ ប្រុងនឹងបោះពុម្ពតទៅ

រឿងដំបងក្រញូង-ក្ងាក្រែក-បក្សីចាំក្រុង
រឿងមេទពត្រិស
រឿងបម្រុះថោងបញ្ចឹមក្រពើ
រឿងព្រះបាទអជាតសត្រូវ
រឿងនិទានទេវទត្ត
រឿងព្រះសុវណ្ណវង្ស

និងសៀវភៅ បាលី-ខ្មែរ ដទៃទៀតជាច្រើន

# សេចក្ដីជូនដំណឹង

បណ្ណាគារខ្ញុំបាទ មានទទួលបង់ក្របសៀវភៅ មានជាព្រះពុទ្ធរូបច្រើនបែប មានជារូបថតផ្សេងៗ គឺព្រះរូបព្រះករុណា និងសម្ដេចសង្ឃនាយកជាដើម និងសៀវភៅធម៌ សៀវភៅរឿង គ្រឿងសរសេរ សង្ឃដិកា ឆាយា សំបុត្រកំណើត កាតកូនសិស្សនិងសៀវភៅបារាំងផ្សេងៗ

សូមនិមន្ត និងអញ្ជើញលោកអ្នកចូលជាវទិញ ដោយមេត្រី ។

បើទិញដុំ យកទៅលក់ទៀត ខ្ញុំគិតរង្វាន់ជូនយ៉ាងគួរសម ។

ថ្លៃ ១២៛០០

) រោងពុម្ព ភិក-ភិ ភ្នំពេញ (